# អាពាហ៍ពិពាហ៍បុរាណខ្មែរ



រូបភាពប្រាសាទបន្ទាយស្រី

រៀបរៀងដោយ

អតីតសាស្ត្រាចារ្យ លី សុវីរ

ភ្នំពេញ

បោះពុម្ពលើកទី១

ព.ស.២៥៥៦ គ.ស.២០១២

www.elibraryofcambodia.org

# អាពាហ៍ពិពាហ៍បង្គ្រប់

## ស្តីពី


~ ពិធីធ្វើក្រួងពាលី ទំព័រ ១២

~ ពិធីចំរើនព្រះបរិត្ត ទំព័រ ១៩

~ ពិធីសែនក្បួចដៃ ទំព័រ ២៣

~ ពិធីកាត់ខាន់ស្លា ទំព័រ ២៥

~ ពិធីលាងជើង ទំព័រ ៣៨

~ ពិធីសំពះផ្ទឹម

~ ពិធីគោងស្បៀ

~ រិះគន់ស្ថាបនា



រៀបរៀងដោយ

អតីតសាស្ត្រាចារ្យ លី សុធីរ



បោះពុម្ពលើកទី ១

ព.ស. ២៥៥៦ គ.ស. ២០១២



www.elibraryofcambodia.org

# អារម្ភកថា

ខ្ញុំបានសិក្សាយល់ច្បាស់ថា ប្រការទាំងឡាយនៃប្រពៃណីអ្វីមួយ ដែលចាស់បុរាណលោកបានអោយអនុវត្ត ហើយរស់នៅបានជាងពីរពាន់ឆ្នាំហើយនោះ យើងត្រូវតែរក្សាទុក, ពីព្រោះខ្ញុំយល់ថា

១. បុព្វបុរសខ្មែរ លោកបានបង្កើតប្រពៃណីអ្វីមួយ លោកបានថ្លឹងថ្លែង ពិចារណា ពិភាក្សាបានល្អិតល្អន់ណាស់, បើប្រពៃណីអាពាហ៍ពិពាហ៍វិញ បើប្រាសចាកពីមូលបញ្ហានៃរបបមាតាធិបតេយ្យខ្មែរ លោកមិនព្រមបង្កើតអោយកូនខ្មែរ យកមកអនុវត្តតាមឡើយ ។

២. ប្រសិនបើប្រពៃណីណានោះ លោកបានអោយអនុវត្តតាមបានជាងពីរពាន់ឆ្នាំ យើងត្រូវតែថែរក្សាទុក ពីព្រោះ ការប្រព្រឹត្តតាមប្រពៃណីនោះ មិនមែនធ្វើអោយមានបាបបុណ្យ រឺមានឧបទ្រព្យចង្រៃអ្វីកើតមានដល់ខ្លួនឡើយដែរ ។

ប៉ុន្តែបើមានពេលខ្លី រឺមានធនធានតិច មិនអាចធ្វើបាន យើងអាចលើកទុកមួយអន្លើសិន រឺយើងយកចំនួនណាមួយមកធ្វើ តាមធនធាន និងពេលវេលាជាការល្អ ពីព្រោះ យើងចេះ និងយល់ប្រពៃណីបានខ្លះហើយ តែក្រែងយើងមិនបានយល់ន័យ នៃពិធីដែលបុព្វបុរសខ្មែរបានបង្កើតអោយយើងអនុវត្ត ។

**បណ្ឌិត លី សុវីរ**

**រក្សាសិទ្ធិ**

www.elibraryofcambodia.org

# ចំណាប់អារម្មណ៍

ខ្ញុំបានអានដោយយកចិត្តទុកដាក់នូវសៀវភៅ

- អាពាហ៍ពិពាហ៍ខ្មែរ ភាគ ១ និងភាគ ២ ឆ្នាំ ១៩៩៥
- អាពាហ៍ពិពាហ៍ខ្មែរកំពុងមានវិបល្លាស ឆ្នាំ ២០០៧
- អាពាហ៍ពិពាហ៍ខ្មែរប្រៀបធៀប ឆ្នាំ ២០០៨
- អាពាហ៍ពិពាហ៍ខ្មែរបន្ថែម ឆ្នាំ ២០១០
- អាពាហ៍ពិពាហ៍ខ្មែរបង្រួប ឆ្នាំ ២០១២

ស្នាដៃស្រាវជ្រាវរបស់លោកបណ្ឌិត ពិតជាមានការលំបាកជាច្រើនណាស់ និងមានទស្សនាទាន ដែលអាចទទួលបាន ហើយនិងអាចឱ្យអ្នកអានទាំងឡាយស្គាល់ ស្រឡាញ់វប្បធម៌ អរិយធម៌របស់ខ្មែរយើង និងជាទិន្នន័យពិសេស ផ្សំ នឹងទិន្នន័យធម្មានុរូបកម្មរាជានិយមខ្មែរ ក្នុងប្រវត្តិសាស្ត្រ ដែលបានធ្វើឱ្យខ្ញុំរកឃើញជាសម្មតិកម្ម នូវលក្ខខណ្ឌរបស់ក្សត្រី លីវ យី ដាក់ទៅលើ ហ៊ុន ទៀន ។

បណ្ឌិត មីន ស៊ាន

www.elibraryofcambodia.org

# ចំណាប់អារម្មណ៍

ខ្ញុំសូមកោតសរសើរដោយស្មោះ ចំពោះលោកព្រឹទ្ធាចារ្យបណ្ឌិត **លី សុវី** ដែលបានខិតខំព្យាយាមធ្វើការសិក្សាស្រាវជ្រាវបានស៊ីជំរៅលើអាពាហ៍ពិពាហ៍ខ្មែរ។ ការណ៍ដែលមាន ឯកសារអាពាហ៍ពិពាហ៍បង្រួប់នេះដោយសារតែគាត់រកឃើញថ្មីៗទៀតដែលមិនទាន់បានសរសេរ និងវិភាគនៅក្នុងស្នាដៃអាពាហ៍ពិពាហ៍ខ្មែរមុនៗរបស់ គាត់។

ឯកសារនេះជាសក្ខីកម្មយ៉ាងប្រត្យក្សបញ្ជាក់យ៉ាងច្បាស់តាមរយៈការរៀបចំពិធីបទចំរៀងនានាក្នុងពេលរៀបអាពាហ៍ពិពាហ៍ថា សង្គមខ្មែរជាសង្គមមាតាធិបតេយ្យដែលបានអោយអំនាចនិងតំលៃដល់នារីខ្មែរថាជាមេ ជាម្ដាយ ជាអ្នកមាន ប្រាជ្ញាឈ្លាសវៃ ម៉ត់ចត់ ឧស្សាហ៍ព្យាយាម សន្សំសំចៃ ជាអ្នករក្សាទុកដាក់ទ្រព្យសម្បត្តិ ជាសិរីសួស្ដី ជាមង្គលនៅក្នុងគ្រួសារ និងសង្គម។

នៅក្នុងទស្សនៈអភិរក្ស និង អភិវឌ្ឍអ្នកដឹកនាំអនុវត្តត្រូវធ្វើយ៉ាងណាអោយរក្សាបានពណ៌សម្បុរប្រពៃណីជាតិមួយដែលធ្លាប់រុងរឿងពីអតីតកាលកាន់តែមានពន្លឺចាំងចែងរុងរោចន៍ថែមទៀត។

សូមអោយប្រពៃណី និងអរិយធម៌ខ្មែររស់នៅ និងរក្សាបានពណ៌សម្បុរជាតិជានិច្ចនិរន្តរ៍។

លី សុម្មនី

www.elibraryofcambodia.org

# ប្រពៃណីខ្មែរ

## ពីនិយមន័យ នៃពាក្យនីមួយៗ

## នៅក្នុងប្រពៃណីអាពាហ៍ពិពាហ៍ខ្មែរ

បុព្វបុរសខ្មែរ បានបង្កើតប្រពៃណីខ្មែរ មានពិធីរៀបអាពាហ៍-ពិពាហ៍កូនចៅជាដើម ទុកអោយកូនចៅខ្មែរធ្វើតាម សុទ្ធតែបានបង្កប់និយមន័យ ជាអត្ថប្បដិរូប ។

ដូចជា ពិធីចំរើនព្រះបរិត្ត, ពិធីសែនគូចដៃ, ពិធីធ្វើធ្មេញ មាន (ពិធីក្រាលអង្កររាប, បុកលក្ខ,...) ពិធីកាត់ខាន់ស្លា, លាងជើង ជាដើម សុទ្ធតែបានបង្កប់និយមន័យ ជាអត្ថប្បដិរូប នៅក្នុងពិធីនីមួយៗនោះ ។

លុះកូនខ្មែរ បានយកប្រពៃណីនីមួយៗនោះ មកអនុវត្តតាម ដោយមិនបានយល់ពីនិយមន័យនោះបានច្បាស់លាស់ ក៏តែងអនុវត្ត តាមភាពស្មានៗខ្លះ ធ្វើអោយការអនុវត្តនោះ មានលក្ខណៈប្លែកៗពីគ្នា ដែលធ្វើអោយមានទំនាស់កើតមាននៅក្នុងសង្គមខ្មែរ ។

ការយល់ឃើញបែបនេះ ទើបខ្ញុំចាប់សរសេរពីនិយមន័យ នៃពាក្យប្រពៃណីអាពាហ៍ពិពាហ៍ខ្មែរ មកពន្យល់តាមលំដាប់ពិធីប្រពៃណីនីមួយៗ ដើម្បីធ្វើអោយកូនខ្មែរ បានយល់ពីបំនងរបស់បុព្វបុរសខ្មែរបាន

www.elibraryofcambodia.org

ច្បាស់ ដើម្បីធ្វើពិធីនីមួយៗនោះ អោយស្របគ្នា ទៅតាមគោលគំនិតរបស់បុព្វបុរសខ្មែរ ដែលបានបង្កើតរបបមាតាធិបតេយ្យ ទុកអោយកូនខ្មែរថែរក្សា ។

## អ្វីហៅថា របបមាតាធិបតេយ្យ?

តើរបបមាតាធិបតេយ្យ កើតមាននៅក្នុងសង្គមខ្មែរ ដោយមានបំនងអ្វី?

គេបានថែរក្សារបបមាតាធិបតេយ្យ នៅក្នុងសង្គមខ្មែរ តើមានលក្ខណះបែបណា? ក្នុងគោលបំនងចង់បានអ្វី?

បណ្តាត្រកូលខ្មែរទាំងអស់ បើត្រកូលខ្មែរណាមួយមានកូនស្រី គេតែងរកពិធីអប់រំកូនស្រីនោះ អោយបានយល់ពីរបបមាតាធិបតេយ្យ តាំងពីកូនស្រីនោះនៅតូច រហូតដល់ចាស់ អោយបានយល់ថា ខ្លួនជាស្រីត្រូវរៀបចំធ្វើខ្លួនបែបណា ដើម្បីធ្វើខ្លួនអោយរស់នៅក្នុងសង្គមមនុស្សមានធម៌មនុស្ស (**សម្ធំ ខន្តី កតញ្ញូ**) សំរាប់ថែរក្សាខ្លួន ។

ដូចនេះ នៅក្នុងសង្គមខ្មែរ ស្រីជាមេសង្គម លោកខំថែរក្សាកូនអោយមានជីវិតរស់នៅបានល្អ មានសុខភាពល្អ បានទទួលចំនេះដឹងពីសង្គមបានល្អ ដូចជាម្តាយ បានអប់រំកូនស្រីអោយមានកាយវិការទន់ភ្លន់ មានវាចាពីរោះ មានរឹកពាសុភាពរាបសា ទៅរកមនុស្សដែលជាចាស់

www.elibraryofcambodia.org

ព្រឹទ្ធាចារ្យ អ្នកមានសុចរិតធម៌ ព្រហ្មចរិយធម៌ សីលធម៌ខ្ពស់នៅក្នុងសង្គម រហូតដល់ចាស់ ។

បើអប់រំកូនស្រីប្រុសបានល្អ លុះត្រាតែព្រះមាតាខ្លួនឯង ចេះធ្វើខ្លួនអោយរស់នៅក្នុងសង្គមខ្លួនបានល្អ មានកាយវិការទន់ភ្លន់ មានវាចាពីរោះពិសា ចេះគោរពចាស់ព្រឹទ្ធាចារ្យ....បានល្អ ទើបអប់រំកូនស្រីប្រុសបានល្អដែរ ។ ប្រសិនបើព្រះមាតាណា ដែលអប់រំខ្លួនអោយរស់នៅក្នុងសង្គមមនុស្សមិនបានល្អ មិនអាចអប់រំកូនស្រីប្រុសបានល្អឡើយ ។

ដូចនេះ នៅក្នុងសង្គមខ្មែរ កាលបើត្រកូលណាមួយ មានកូនស្រី, ត្រកូលខ្មែរ រឺសង្គមខ្មែរ ត្រូវជួយអប់រំកូនស្រី ដែលបានកើតក្នុងសង្គមខ្មែរ រឺត្រកូលខ្មែរ អោយរស់នៅបានល្អ គឺអោយមានវាចាពីរោះ មានកាយវិការទន់ភ្លន់ មានរីកពាសុភាពរាបសា តាំងពីនៅតូចរហូតដល់ចាស់ព្រឹទ្ធាចារ្យ ចំពោះមនុស្សស្រី ដែលជាអ្នកដឹកនាំសង្គមមនុស្សខ្មែរបន្តទៅទៀត ។

## ការបង្កើតរបបមាតាធិបតេយ្យ

កាលបើសង្គមខ្មែរ បានអប់រំកូនស្រីខ្មែរ អោយបានចេះយល់ពីបញ្ហារស់នៅក្នុងសង្គមខ្មែរបានល្អហើយ ទើបលោកបង្រៀនពីកិរិយាមារយាទថ្លៃថ្នូរ សំរាប់ជាតិខ្មែរ, លោកបានអោយតំលៃលើស្រីណាដែល

www.elibraryofcambodia.org

ចេះថែរក្សាព្រហ្មចរិយធម៌របស់ខ្លួន ដែលជាកិត្តិយសសំរាប់ជាតិខ្មែរទាំងមូល គឺមិនធ្វើអោយខូចបង់កិត្តិយសដល់ជាតិខ្មែរទាំងអស់ ។

ស្រីបែបនេះ បើនាងអញ្ជើញទៅទីណា មកទីណា គេកោតសរសើរស្ញប់ស្ញែង គេខ្លបខ្លាច ពពួកទេវតាអោយពរ ព្រះព្រហ្មអោយជ័យ សិរីមង្គល កើតមានដល់នាងគ្រប់ពេលវេលា ។

**តើស្ត្រីមានលក្ខណៈបែបណា ដែលលោកហៅថា ចេះថែរក្សាព្រហ្មចរិយធម៌របស់ខ្លួន? តើព្រហ្មចរិយធម៌ជាអ្វី?**

បើតាមការសង្កេត នៅក្នុងសង្គមខ្មែរក្តី តាមដំនើររឿង ដែលមាននៅក្នុងសង្គមខ្មែរក្តី លោកបានអោយតំលៃថា ជានារីគ្រប់លក្ខណ៍បាន, លុះត្រាតែនារីនោះ មានៈ

- កាយវិការទន់ភ្លន់
- វាចាពីរោះពីសា
- ចិត្តស្លូតបូត
- រីកពាសុភាពរាបសា
- ចិត្តស្មោះត្រង់ ចំពោះសង្គមមនុស្ស
- អំនត់ធ្មត់ ចំពោះការងារ
- អំនត់ធន់ ចំពោះសេចក្តីស្នេហា,... ។

www.elibraryofcambodia.org

### តើអំនត់ធន់ ចំពោះសេចក្តីស្នេហា មានលក្ខណៈបែបណា?

ធម្មតាមនុស្សស្រីក្តី ប្រុសក្តី សុទ្ធតែមានសេចក្តីស្នេហា ជាប្រចាំនៅក្នុងខ្លួន។ តែស្រីខ្មែរ លោកមានត្រណម (វិន័យ) ចំពោះសេចក្តីស្នេហាថា បើស្រីខ្មែរណា មានស្នេហា ចំពោះបុរសណាម្នាក់ ដោយគ្មានការអនុញ្ញាតពីលោកមេបា សង្គមខ្មែរបានដាក់ទោសធ្ងន់ណាស់ ។

ស្រីខ្មែរមានរីកពាសុភាពរាបសា, បើប្រុសណាបានចូលទៅនិយាយពីស្នេហាចំពោះនាង ដោយមិនបានឆ្លងកាត់តាមរយៈលោកមេបាទេ នាងមិនព្រមនិយាយតបវិញ។ នាងបានធ្វើរីកពាធម្មតាសំដែងអាការធ្វើមិនដឹងមិនលឺ។ តែបើប្រុសនិយាយពាក្យណា ក្រៅពីសេចក្តីស្នេហា នាងឆ្លើយតបជាធម្មតា ។

ការឃើញរីកពានាងបែបនេះ រឹតតែធ្វើអោយគេស្រលាញ់នាងខ្លាំងឡើងៗ មិនអាចអត់ទ្រាំបាន ទើបទៅជំរាបម្តាយឪពុក។ បើម្តាយឪពុកបានដឹង ទើបម្តាយឪពុក រៀបចំទាក់ទងតាមប្រពៃណី ទៅនឹងម្តាយឪពុកកូនស្រី បើម្តាយឪពុកកូនស្រី អនុញ្ញាតអោយទាក់ ទង ទើបម្តាយឪពុកកូនប្រុស រៀបចំប្រដាប់ប្រដា ទៅស្តីដណ្តឹងកូន ស្រី។ បើម្តាយឪពុកកូនស្រីយល់ព្រម ត្រូវរៀបការកូនស្រីប្រុស អោយបានគ្នាជាប្តីប្រពន្ធ ។

www.elibraryofcambodia.org

លុះសំពះផ្ទឹមរួច នៅពេលក្រោកឡើង ប្រុសត្រូវដើរអោនគោង កន្ទុយស្បៃកូនស្រីរហូតដល់ក្នុងបន្ទប់ បានន័យថា ប្រុសត្រូវធ្វើអ្វីៗ តាមមតិល្អប្រពៃរបស់ប្រពន្ធ ពីព្រោះស្រីជាមេសង្គម ដឹកនាំសង្គម។ បើរកទ្រព្យបាន ត្រូវប្រគល់អោយប្រពន្ធជាអ្នកទុកដាក់ ។

ស្រីដែលមានលក្ខណៈដូចខាងលើនេះហើយ លោកហៅថា របប មាតាធិបតេយ្យ ដោយលោកយល់ថា ស្រីជាមេសង្គម នៃត្រកូល នីមួយៗរបស់ខ្មែរ ។

ការយល់បែបខាងលើនេះហើយ ទើបសង្គមខ្មែរ កាលបើត្រកូល ណាមានកូនស្រី ម្តាយឪពុកក្តី មាមីង បងប្អូនទាំងអស់ក្តី ត្រូវជួយអប់រំ កូនស្រីនៅក្នុងត្រកូលខ្លួន សង្គមខ្លួន ជួយអប់រំកូនស្រីនោះ អោយបាន ល្អ សំរាប់ដឹកនាំត្រកូលសង្គមខ្មែរបន្តទៅទៀត ។

បើត្រកូលណាមានកូនស្រី អប់រំកូនស្រីនោះមិនបាន កូននោះ បានប្រព្រឹត្តអនាចារ។ តាមការនិយមរបស់ខ្មែរ តាមប្រពៃណីថា បើនៅ ក្នុងត្រកូលខ្មែរ រឺសង្គមខ្មែរនោះ បើមានអ្នកណាឈឺ គេបានហៅកូនស្រី នោះ ទៅសែនគោរពជីដូនជីតាអោយគេ ពីព្រោះ ជីដូនជីតាខឹង បានធ្វើ អោយឈឺ ពីព្រោះខឹងអ្នកនោះ មិនជួយអប់រំកូនស្រីនោះអោយបានល្អ ។

www.elibraryofcambodia.org

កូនស្រីបានប្រព្រឹត្តអាក្រក់បែបនេះ ត្រកូលរីសង្គមខ្មែរ មិនព្រមទទួលស្គាល់កូនស្រីនោះថា ជាមនុស្សល្អ នៅក្នុងសង្គមខ្មែរឡើយ លោកបានចាត់ទុកថា ជាមនុស្សបំព្រៃសង្គម នៅពេលរៀបអាពាហ៍-ពិពាហ៍កូនខ្មែរណាម្នាក់ គេមិនអោយកូនស្រីនោះ ចូលទៅប៉ះទេយ្យវត្ថុណាមួយឡើយ ។ បើនៅពិធីបង្វិលពពិលវិញ គេមិនអោយចូលទៅជិតទាល់តែសោះ ។ សង្គមខ្មែរស្អប់ស្រីអនាចារបែបនេះណាស់ ។

បើស្រីល្អ មិនត្រឹមតែនៅរស់ទេ សូម្បីស្លាប់ហើយ ក៏នៅតែគេតាមគោរពទៀត ឧ. នៅពេលរៀបអាពាហ៍ពិពាហ៍ មានបង្គាប់ប្រាក់ថ្លៃស្នាប់ទឹកដោះ (មើលក្បួនអាពាហ៍ពិពាហ៍មហាមន្ត្រី ញ៉ុក នូវ) ។ តែការបង្គាប់នោះ ត្រូវមើលត្រកូលខាងប្រុស មិនអោយបង្គាប់ច្រើនពេកទេ តែបើតិចនោះ ត្រឹមនិមន្តព្រះសង្ឃ ១ អង្គ មកធ្វើបុណ្យសង្ឃទានបាន ។

ប្រាក់ថ្លៃស្នាប់ទឹកដោះនោះ ត្រូវជូនទៅម្តាយ ដើម្បីអោយម្តាយយកប្រាក់នោះ ធ្វើបុណ្យសង្ឃទានជូនម្តាយ ជីដូន,... ។ បើម្តាយស្លាប់ ត្រូវជូនទៅឪពុក ។ ឪពុកត្រូវយកប្រាក់នោះ ទៅធ្វើបុណ្យសង្ឃទាន ឧទ្ទិសកុសលជូនទៅម្តាយ ជីដូន ជីដូនទួត, លួត,... តែ ឪពុក,

www.elibraryofcambodia.org

ជីតា, ជីតាទួត,.... ក្បួនគ្មានបានប្រាប់ថា ត្រូវឧទ្ទិសជូនឡើយ ពីព្រោះ ប្រុសគ្មានចិញ្ចឹមកូនដោយទឹកដោះ ។

របបមាតាធិបតេយ្យនៅក្នុងសង្គមខ្មែរ តាំងពីនៅតូច ត្រូវគេគោរពស្រីជាងប្រុស រហូតដល់ស្លាប់បាត់ហើយ ក៏គេនៅតាមគោរពបន្តទៅទៀត ។

បើសង្គមណា បានគោរពប្រតិបត្តិតាមបែបខាងលើនេះបាន លោកហៅសង្គមនោះថា ជាសង្គមមាតាធិបតេយ្យ ។

នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍កូនចៅខ្មែរ មានពិធីតូចៗជាច្រើន, ប៉ុន្តែ នៅក្នុងទីនោះ ខ្ញុំសូមលើកយកតែពិធីណា ដែលខ្ញុំបានយល់ថា ពិធីនោះ នៅមានបញ្ហាទំនាស់គ្នា មិនមានឯកភាពគ្នាសោះ ទើបខ្ញុំខំយកបញ្ហានោះ មកសរសេរដោះស្រាយ បង្កើតអោយមានទស្សនៈរិះគន់ សំរាប់ពិចារណារកខុសត្រូវ ។

ឯបញ្ហាដែលខ្ញុំបានលើកយកមកសរសេរនោះ មាន :


១. បង្ហាញពីរបបមាតាធិបតេយ្យ ទំព័រ ១០

២. ពិធីធ្វើក្រុងពាលី ទំព័រ ១២

៣. ពិធីចំរើនព្រះបរិត្ត ទំព័រ ១៩

៤. ពិធីសែនក្មួចដៃ ទំព័រ ២៣


www.elibraryofcambodia.org

៥. ពិធីកាត់ខាន់ស្លា ទំព័រ ២៥
៦. ពិធីលាងជើង ទំព័រ ៣៧
៧. ពិធីសំពះផ្ទឹម
៨. ពិធីគោងស្បៃ
៩. សូមរិះគន់ស្ថាបនា ។

CAMBODIAN • EDUCATION • EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION

www.elibraryofcambodia.org

## ក. បញ្ហាញពីរបៀបមាតាធិបតេយ្យ
## នៅក្នុងសង្គមខ្មែរ

- ពិធីចែចូវ នាំសំដីទៅមក មុននឹងចូលទៅស្ដីដណ្ដឹងកូនក្រមុំគេ ត្រូវរកមនុស្ស ដែលមានលក្ខណៈស្របតាមប្រពៃណីខ្មែរ ចូលទៅទាក់ទងជាមុនសិន ។

- ស្ដីដណ្ដឹង ស្ដីនិយាយអោយគេដឹង សាកសួរអោយគេដឹង របៀបនិយាយចងស្ពានមានមេត្រី ក្នុងគោលបំនងផ្សំផ្គុំកូនស្រីប្រុស អោយជាគូភរិយាស្វាមី ។

- ពិធីហែកំនត់ គឺហែយកភស្ដុភារបណ្ណាការ ទៅជូនលោកមេបា តាមការដែលបានសន្មតគ្នា ដើម្បីធ្វើអោយម្ដាយឪពុក ជីដូនជីតា ញាតិមិត្ត ពេញចិត្ត ប្រគល់កូនស្រីអោយមកខ្លួន ធ្វើជាប្រពន្ធ ។

- ពិធីជូនប្រាក់ខាន់ស្លា (ប្រាក់ថ្លៃផ្ទះ) ជូនទៅលោកមេបា ដោយគោរព ។

- ពិធីជូនប្រាក់ស្មាប់ទឹកដោះ ទៅម្ដាយកូនស្រី អោយធ្វើបុណ្យសង្ឃទាន ជូនវិញ្ញាណ ជីដូន, ជីដូនទួត, ជីដូនលួត, ជីដូនលា,... ។

ការធ្វើបែបនេះ ទើបគេនិយាយរក, ទើបគេអោយកូនស្រីមកកូនប្រុស ។

មូលនិធិខ្មែរសម្រាប់ការសិក្សា FOUNDATION

www.elibraryofcambodia.org

ដោយមានការយល់ឃើញបែបណា បានជាមុននឹងរៀបធ្វើមង្គលណាមួយ គេត្រូវរៀបចំធ្វើពិធីសែនក្រុងពាលីជាមុនសិន ទើបរៀបចំធ្វើពិធីនោះជាក្រោយ ពីព្រោះលោកយល់ថា ស្តេចក្រុងពាលី ជាអ្នកបង្កើតទឹក បង្កើតដី ជាអ្នកថែរក្សាទឹកដី ។

បើយករឿងនេះមកប្រៀបនឹងសម័យសព្វថ្ងៃ ស្តេចក្រុងពាលីជារដ្ឋអំណាច ជាអ្នកមើលការខុសត្រូវ លើមនុស្សអ្នករស់នៅលើផែនដី។

ដូចនេះ មុននឹងធ្វើអ្វីៗ ត្រូវរៀបចំសែនក្រុងពាលី ជំរាបស្តេចក្រុងពាលីជាមុនសិន ដើម្បីអោយស្តេចក្រុងពាលី ទទួលស្គាល់។ ស្តេចក្រុងពាលី នឹងអោយពរ អោយជ័យ សិរីមង្គលដល់ខ្លួន ។

មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION

**បញ្ជាក់**

តើពិធីធ្វើក្រុងពាលីនៅពេលណា?

នៅពេលមុនកូនប្រុស ចូលដល់ផ្ទះកូនស្រី ។

បុរាណ លោករៀបការ ៣ ថ្ងៃ លោកធ្វើនៅថ្ងៃទី ២ មុនពេលហែកំនត់ទៅជូនលោកមេបា ។

បច្ចុប្បន្ន លោករៀបការ ២ ថ្ងៃ នៅពេលល្ងាចនៃថ្ងៃទី ១ លោកច្រើនធ្វើនៅម៉ោង ៣ រសៀល នៅពេលមុននិមន្តព្រះសង្ឃចំរើនព្រះបរិត្ត ។

www.elibraryofcambodia.org

# ១. ពិធីធ្វើក្រុងពាលី

តើក្រុងពាលីជាអ្វី? មាននិយមន័យបែបណា? សរសេរដូចម្តេច?

ពាក្យក្រុងពាលី មកពីពាក្យ **ក្រុង** : **ស្តេច** + **ពាលី** : ឈ្មោះ រួមសេចក្តីមក **ស្តេចពាលី** ។ តើស្តេចពាលី ជាអ្វី?

បើយោងតាមសាស្ត្រាធម្មតាមហាអនន្តគុណខ្មែរ ៥ ផ្នែកខាងដើម មាននិយាយពីប្រវត្តិធ្វើក្រុងពាលី និងធ្វើរានទេវតា ។

- មូលហេតុអ្វី បានជាធ្វើក្រុងពាលី?
- មូលហេតុអ្វី បានជាធ្វើរានទេវតា ៨ ទិស?

សម័យថ្ងៃមួយ មានភ្លើងឆេះកល្ប៍, ឆេះអស់មនុស្ស, សត្វ, រុក្ខាលតាវល្លិ៍, អ្វីៗ ក៏ឆេះគ្មានសល់ មាននៅសល់តែទឹកល្ហល្ហេវ។ នៅពេលនោះ ព្រះពាយបោកបក់ចុះឡើង បង្កើតបានជាពពុះទឹក រសាត់អណ្តែតចុះឡើង គ្មានទីបំផុត ។

នៅពេលនោះ មានមហាកាលនាគរាជ ១ ឈ្មោះ ក្រុងពាលី និងព្រះអនុជម្នាក់ឈ្មោះ ភូមិរាជ ជាអ្នកនៅថែរក្សាទឹកនោះ។ លុះបានឃើញពពុះទឹកអណ្តែតចុះឡើងដូចនោះ ក៏បបួលបងប្អូនគួចកន្ទុយគ្នា ពេនពង់ក្រុងពពុះទឹកនោះ កុំអោយអណ្តែតទៅណា។ យូរទៅពពុះ

www.elibraryofcambodia.org

ទឹកនោះ ក៏បានកកទៅជាដែនដី ដុះព្រៃព្រឹក្សាលតាវល្លិ៍ មានមនុស្ស មានសត្វ សព្វបែបយ៉ាង ។

នៅសម័យនោះ មានព្រះពុទ្ធទ្រង់ព្រះនាម **បទុមុត្តរះ** បាន ត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គបានឈ្វេងយល់ថា ផែនដីនេះ បាន កើតអំពី មហាកាលនាគរាជ ឈ្មោះ ក្រុងពាលី ។ ព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរះ ទ្រង់បានជ្រាបដូចនោះ ក៏ព្រះអង្គយាងទៅបិណ្ឌបាតផែនដី ៣ ជំហាន ពីស្តេចក្រុងពាលី ដើម្បីអោយពុទ្ធបរិស័ទ បានរស់នៅលើ ផែនដីនោះផង ។

ស្តេចក្រុងពាលីយល់ថា ផែនដី ៣ ជំហាន មានភាពតូចណាស់ ក៏ស្តេចក្រុងពាលី លើកថ្វាយព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរះ។ ព្រះ ពុទ្ធទ្រង់ប្រកាសប្រាប់ពពួកទេវតាទាំង ៨ ទិសថា ស្តេចក្រុងពាលី (ព្រហ្ម) ព្រមថ្វាយដី ៣ ជំហានដល់តថាគត ។

ព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរះ ព្រះអង្គបានឈាន ៣ ជំហាន អស់ដីក្រុងពាលីរលីង។ ព្រះអង្គទ្រង់អនុគ្រោះ បញ្ជាអោយស្តេច ក្រុងពាលី ទៅនៅព្រៃហេមពាន្ត ។

www.elibraryofcambodia.org

ទឹកនោះ ក៏បានកកទៅជាដែនដី ដុះព្រៃព្រឹក្សាលតាវល្លិ៍ មានមនុស្ស មានសត្វ សព្វបែបយ៉ាង ។

នៅសម័យនោះ មានព្រះពុទ្ធទ្រង់ព្រះនាម **បទុមុត្តរៈ** បាន ត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គបានឈ្វេងយល់ថា ផែនដីនេះ បាន កើតអំពី មហាកាលនាគរាជ ឈ្មោះ ក្រុងពាលី ។ ព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរៈ ទ្រង់បានជ្រាបដូចនោះ ក៏ព្រះអង្គយាងទៅបិណ្ឌបាតផែនដី ៣ ជំហាន ពីស្តេចក្រុងពាលី ដើម្បីអោយពុទ្ធបរិស័ទ បានរស់នៅលើ ផែនដីនោះផង ។

ស្តេចក្រុងពាលីយល់ថា ផែនដី ៣ ជំហាន មានភាពតូចណាស់ ក៏ស្តេចក្រុងពាលី លើកថ្វាយព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរៈ។ ព្រះ ពុទ្ធទ្រង់ប្រកាសប្រាប់ពពួកទេវតាទាំង ៨ ទិសថា ស្តេចក្រុងពាលី (ព្រហ្ម) ព្រមថ្វាយដី ៣ ជំហានដល់តថាគត ។

ព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរៈ ព្រះអង្គបានឈាន ៣ ជំហាន អស់ដីក្រុងពាលីរលីង។ ព្រះអង្គទ្រង់អនុគ្រោះ បញ្ជាអោយស្តេច ក្រុងពាលី ទៅនៅព្រៃហេមពាន្ត ។

www.elibraryofcambodia.org

ស្តេចក្រុងពាលី ទ្រង់យាងចេញទៅនៅព្រៃហេមពាន្តតាមព្រះបន្ទូល តែស្តេចក្រុងពាលី នឹកស្តាយផែនដីនោះណាស់ ។ ស្តេចក្រុងពាលីបានប្រើព្រះភូមិរាជ អោយទៅសុំបាយពៃចែង ពែពលី ពីព្រះអង្គ ។

ព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរៈ ព្រះអង្គទ្រង់អនុលោមផ្តាំថា បើបុរសស្រីណា បានធ្វើបុណ្យអ្វីមួយ ត្រូវធ្វើពៃចែង ពែពលី ដាក់ទេយ្យវត្ថុ មាននំចំណី អាហារភោជន បូជាស្តេចក្រុងពាលី ព្រះអង្គបានសំដែងថា បានកុសលផលានិសង្សច្រើនណាស់ ។ បើមិនបានធ្វើពៃចែងពែពលីថ្វាយស្តេចក្រុងពាលីទេ ព្រះភូមិរាជនឹងមានព្រះទ័យអាក់អន់រិះគន់ ជេរប្រទេចផ្តាសា យកកន្ទុយវាយវាត់ ពុំបានផលឡើយ ។

លុះព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរៈ ទ្រង់បានអនុញ្ញាតអោយពុទ្ធបរិស័ទទាំងអស់ថា បើបានធ្វើមង្គលអ្វីមួយ ត្រូវធ្វើពៃចែង ពែពលីថ្វាយស្តេចក្រុងពាលី ទើបបានបុណ្យ បានផលានិសង្សច្រើន ។

ពពួកទេវតាទាំង ៨ ទិស បានធ្វើជាកសិណ ដែលព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរៈ ទ្រង់ប្រកាសជាមួយនឹងស្តេចក្រុងពាលី ។ ឯស្តេចក្រុងពាលី បានសុំអោយព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរៈ ទ្រង់ផ្តាំនឹងពុទ្ធបរិស័ទថា បើបុរសស្រីណា បានធ្វើពិធីមង្គលអ្វីមួយ ត្រូវអោយធ្វើភានទេវតាទាំង ៨ ទិស ព្រមទាំងអោយរៀបរណ្តាប់ នំចំណី

www.elibraryofcambodia.org

២. អតិថិពលី     ការទទួលភ្ញៀវ

៣. បុព្វបេតពលី ការធ្វើទានឧទ្ទិសផល ជូនអ្នកដែលបានចែកឋានទៅបរលោកនាយហើយ

៤. រាជពលី ការទទួលភារកិច្ចរាជការ ថ្វាយសួយសា អាករចំពោះព្រះរាជា មានបង់ពន្ធដារផ្សេងៗ

៥. ទេវតាពលី ការផ្សាយចំនែកបុណ្យចំពោះទេវតា តាមលទ្ធិព្រះពុទ្ធសាសនា, ការរៀបភោជនាហារថ្វាយទេវតា តាមលទ្ធិក្រៅព្រះពុទ្ធសាសនា ។

អ្នកយល់តាមបែបខាងលើ លោកបានសរសេរពាក្យ **ក្រុងពលី** ។

តាមសង្កេត ឃើញមានការប្រើពាក្យតាមការយល់ឃើញរបស់ខ្លួនថា ក្រុងពាលី និងក្រុងពលី ។

ដូចនេះ យើងត្រូវយកពាក្យទាំង ២ នេះ មកវិភាគ, តើពាក្យណាខុស តើពាក្យណាត្រូវ?

ពាក្យក្រុងពលី មកពីពាក្យ ក្រុង = ស្តេច, ពលី = ការបូជា ។

តើយើងយកពលីទាំង ៥ ពលីណាមួយមកធ្វើជាស្តេច?

តាមគោលបំនងអ្នកធ្វើ រឺអ្នករកគេអោយមកធ្វើ តើគេចង់បានអ្វី? រឺគេចង់អោយទទួលភ្ញៀវ រឺគេចង់អោយយើងបង់ពន្ធជូនរដ្ឋ?

www.elibraryofcambodia.org

បើតាមគោលបំណងអ្នកធ្វើ រឺអ្នករកគេអោយមកធ្វើ តើគេចង់បានអ្វី? គេចង់បានសេចក្តីសុខចំរើនពីអ្នកណាម្នាក់ ដែលបានផ្តល់សេចក្តីសុខចំរើនអោយគេ ។

បើសង្កេតតាមពាក្យពលីទាំង ៥

១. ពាក្យពលីទាំង ៥ គ្មានពាក្យណាមួយ ជាការកនាមទេ មានតែជាពាក្យករណនាម។ ដូចនេះ ពាក្យពលីទាំង ៥ មិនអាចទៅជួយផ្តល់សេចក្តីសុខ សេចក្តីចំរើន ដល់អ្នកណាម្នាក់បានឡើយ ។

២. ពាក្យពលីទាំង ៥ ជាពាក្យសំរាប់បុគ្គលណាម្នាក់ បានធ្វើការបូជាដោយគោរព ចំពោះនរណាម្នាក់ប៉ុណ្ណោះ ។

ដូចនេះ អ្នកយកពាក្យពលីមកប្រើ មិនត្រឹមត្រូវតាមដំនើររឿងទេ ។

**បញ្ជាក់**

ពិធីធ្វើក្រុងពាលីនេះ ចាប់ពីឆ្នាំ ១៩៤៥ មក ព្រះពុទ្ធសាសនាកំពុងមានការរីកចំរើនខ្លាំង ពិធីក្រុងពាលី ចេះតែចុះថយទៅៗ រហូតដល់បាត់ឈឹង មានលោកអាចារ្យខ្លះ ប្រជាជនខ្លះ មិនដែលលឺពាក្យក្រុងពាលីនេះផងក៏មាន ។

www.elibraryofcambodia.org

លុះដល់ចុងទសវត្សទី ៨ និងដើមទសវត្សទី ៩ នៃសតវត្សទី ២០ នេះ ទើបបានចាប់រស់ឡើងវិញ ។

កាលបើធ្វើពិធីក្រុងពាលីចប់ លោកចាប់យកពិធីផ្សេងៗ មកធ្វើជាបន្តបន្ទាប់ ៖

១. ពីសម័យបុរាណ បន្ទាប់ពីពិធីក្រុងពាលី លោកធ្វើពិធីហៃកំនត់ទៅជូនលោកមេបា ។

២. សម័យបច្ចុប្បន្ន បន្ទាប់ពីពិធីធ្វើក្រុងពាលី លោកធ្វើពិធីចំរើនព្រះបរិត្ត ។

មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION

www.elibraryofcambodia.org

## គ. ពិធីចំរើនព្រះបរិត្ត

នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ខ្មែរ គ្មានរឿងអ្វី ទាក់ទងនឹងព្រះសង្ឃសោះ ហេតុអ្វីក៏និមន្តព្រះសង្ឃមកចំរើនព្រះបរិត្តដែរ។ តើមានមូលហេតុអ្វី? មកពីមានគោលបំនងអ្វី?

ប្រទេសខ្មែរអ្នកកាន់ព្រះពុទ្ធសាសនា បើមានរៀបធ្វើពិធីអ្វីមួយត្រូវតែនិមន្តព្រះសង្ឃមកចំរើនព្រះបរិត្ត ។

### ក. នៅសម័យបច្ចុប្បន្ន

គេនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត ដោយមានគោលបំនង ចង់បានព្រះសង្ឃសូត្រធម៌ ប្រសិទ្ធពរជ័យ អោយកូនស្រី កូនប្រុស បានសុខចំរើន ។

### ខ. នៅសម័យបុរាណ

គេបាននិមន្តព្រះសង្ឃចំរើនព្រះបរិត្ត អភិសេកកូនស្រី កូនប្រុសអោយបានជាមនុស្ស ។

នៅពេលរៀបអាពាហ៍ពិពាហ៍ តើកូនស្រី កូនប្រុស មិនមែនជាមនុស្សទេវី?

www.elibraryofcambodia.org

បើយើងនាំគ្នាមើលរូបកូនស្រី កូនប្រុស ឃើញគេមានរូបមនុស្សជាស្រី ជាប្រុសច្បាស់ណាស់ តែយើងមិនអាចសន្និដ្ឋានថា អ្នកទាំង ២ នាក់នេះ មានធមិមនុស្សហើយ រឺនៅ?

**តើធម៌មនុស្ស មានអ្វីខ្លះ?**

១. សច្ចំ ធ្វើអោយអ្នកទាំង ២ នាក់ មានវាចាប្រកាន់សច្ចភាព ទោះនិយាយទៅកាន់ប្តីប្រពន្ធក្តី ទៅកាន់សង្គមមនុស្សក្តី អ្នកទាំង ២ ប្រកាន់សច្ចភាពទាំងអស់ ។

២. ខន្តី ត្រូវមានការអត់ធ្មត់ចំពោះគ្នានិងគ្នា ត្រូវពិចារណារកហេតុផលអោយបានច្បាស់ បើហេតុការណ៍នោះ មិនប៉ះពាល់សង្គមមនុស្សខ្លាំងទេ ត្រូវតែចេះអត់ធ្មត់ ទើបរកសេចក្តីសុខជូនសង្គម និងសង្គមគ្រួសារបាន ។

៣. កតញ្ញូ មានភាពជាមនុស្សអ្នកមិនរមិលគុណគេ ដែលគេបានធ្វើមកលើខ្លួន មានព្រះមាតាបិតា ជាដើម ។

បើអ្នកណាម្នាក់ មានធមិ សច្ចំ ខន្តី កតញ្ញូ នៅក្នុងខ្លួន លោកហៅថាមនុស្ស ។ បើអ្នកទាំង ២ មានធមិនៅក្នុងខ្លួនហើយ អ្នកទាំង ២ មិនចេះឈ្លោះប្រកែកគ្នា អ្នកទាំង ២ មិនចេះឈ្លោះប្រកែកនឹងអ្នកដទៃ

www.elibraryofcambodia.org

ឡើយ ។ ពីព្រោះ អ្នកទាំង ២ បានយល់ពីសង្គមមនុស្ស រៀនចេះរស់នៅក្នុងសង្គមមនុស្សបានល្អ ។

ការដាក់ផ្តិលទឹក នៅក្នុងពិធីចំរើនព្រះបរិត្ត ក្នុងគោលបំនងអោយព្រះសង្ឃបាចទឹកអោយកូនស្រីប្រុស ។ ការធ្វើនេះ ក្នុងគោលបំនង ចង់បានសេចក្តីសុខចំរើនអោយកូនស្រីប្រុស ។

តែការធ្វើនេះ ត្រូវជួបនឹងវិបត្តិ ២ យ៉ាង :

១. នៅពេលរៀបអាពាហ៍ពិពាហ៍ នៅសម័យនេះ ច្រើនតែជួលយកសំលៀកបំពាក់ពីផ្ទះ មកស្លៀកពាក់ ។ ពេលព្រះសង្ឃបាចទឹកមន្តត្រូវសំលៀកបំពាក់ទទឹកជោគ អ្នកផ្ទះមានទឹកមុខមិនល្អ អ្នកផ្ទះខ្លះយកសំពត់ទៅគ្របបិទបាំង កុំអោយទទឹកសំលៀកបំពាក់ ។

ការធ្វើរបៀបនេះ ច្រើនគេទិចទានថា ប្រពៃណីខ្មែរមិនល្អ ។ ឯព្រះសង្ឃធ្វើកាយវិការច្រងេងច្រងាង ពុទ្ធបរិស័ទថា ព្រះសង្ឃមានកាយវិការមិនល្អផង ។

ដើម្បីជៀសវាងហេតុទាំង ២ នេះ ផ្ទះគួរធ្វើញ៉ាវស្រា មានរាងដូចកូនប៉ាន់ សំរាប់ដាក់ទឹកក្លស់ ទឹកសង្ខ នៅមុខព្រះសង្ឃ ។

លុះព្រះសង្ឃសូត្រមន្តចប់ កូនស្រីប្រុស យកទេយ្យវត្ថុទៅប្រគេនព្រះសង្ឃ ថ្វាយបង្គំព្រះសង្ឃ លាបាតដៃទាំងគូទៅរកព្រះសង្ឃ,

www.elibraryofcambodia.org

ព្រះសង្ឃយកទឹកក្លស់ ទឹកសង្ខ ច្រូចដាក់បាតដៃកូនស្រីប្រុស។ កូនស្រីប្រុសយកទឹកក្លស់ ទឹកសង្ខ មកលាបមុខ ក្បាល។ ការធ្វើបែបនេះ ក៏មានលក្ខណៈល្អម្យ៉ាងដែរ ហើយមានលក្ខណៈស្របតាមប្រពៃណីខ្មែរផង ។

អ្នកផ្សង គួរធ្វើកូនប៉ាន់ដាក់ទឹកក្លស់ ទឹកសង្ខ ដើម្បីជៀសវាងកុំអោយទឹកមន្ត ទទឹកសំលៀកបំពាក់ ខូចខោអាវរបស់ខ្លួនផង ដើម្បីការពារព្រះសង្ឃកុំអោយព្រះអង្គមានកាយវិការច្រងេងច្រងាងផង ។

**បញ្ហាក់ពីការនិមន្តព្រះសង្ឃ**

នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ តើលោកត្រូវនិមន្តព្រះសង្ឃប៉ុន្មានព្រះអង្គ?

**១. នៅសម័យបុរាណ**

លោកនិមន្តពីចំនួន ៥ ទៅ ៨ ព្រះអង្គ ពីព្រោះលោកយល់ថានិមន្តព្រះសង្ឃមកអភិសេកអ្នកទាំង ២ នាក់ អោយបានជាមនុស្ស ។

**២. បច្ចុប្បន្ន**

លោកយល់ថា និមន្តព្រះសង្ឃមកចំរើនព្រះបរិត្ត ប្រសិទ្ធពរជ័យអោយកូនស្រីប្រុស និមន្ត ២ ព្រះអង្គក៏បាន ៥ ព្រះអង្គក៏បាន តាមសទ្ធា មិនមានកំនត់ឡើយ ។

មូលនិធិខ្មែរសម្រាប់ការសិក្សា FOUNDATION

## ឃ. ពិធីសែនគួចដៃ

ពិធីសែនគួចដៃនេះ ពីសម័យបុរាណ លោកបានរៀបពិធីដាច់ដោយឡែកពីគ្នា គឺកូនស្រី បានរៀបពិធីសែននៅលើផ្ទះកូនស្រី។ លុះសែនកូនស្រីរួច ទើបលោកមេបាទាំងអស់ នាំគ្នាចុះទៅសែនកូនប្រុសនៅឯរោងផ្កាស្លាទៀត ។

ហេតុអ្វី ក៏បានជាលោករៀបពិធីសែនដាច់ដោយឡែកពីគ្នា?

ពីព្រោះ កូនស្រីត្រូវសែនជំរាបប្តីងញាតិខាងស្រី, ឯកូនប្រុសត្រូវសែនជំរាបប្តីងញាតិខាងកូនប្រុស ទោះញាតិនោះ មានជីវិតរស់នៅក្តី បានស្លាប់បាត់បង់ជីវិតទៅហើយក្តី សូមអោយក្រុមញាតិទាំងនោះទទួលស្គាល់ខ្លួនថា បានរៀបអាពាហ៍ពិពាហ៍ បានក្រាបក្បាលដល់កន្ទេលគោរពជីដូនជីតា ។

ឯញាតិកំពុងមានជីវិតនៅរស់ លោកបានយកអំបោះស ៣ សរសៃ មកគួបគ្នា ហើយគួចកណ្តាលមកចងដៃកូនប្រុសស្រី ថែមទាំងប្រកាសប្រាប់អ្នកទាំងពីរថា តា, អុំ ចងស្រែនេះ, គោនេះ រឺក្របីនេះ រឺជាមាស រឺជាប្រាក់ ទុកជាដើមទុនរបស់អ្នកទាំង ២ ផង ។

ម្យ៉ាងទៀត លោកបានកោតសរសើររឹកពា ចរិយា នៃអ្នកទាំង ២ ថាជាមនុស្សមានរឹកពាល្អ បានគោរពប្រពៃណីខ្មែរ បានល្អប្រពៃផង ។

www.elibraryofcambodia.org

លោកបានអធិដ្ឋានចិត្តថា សូមអោយអ្នកទាំង ២ បានសុខចំរើន ដូចបំនងប្រាថ្នារៀងៗខ្លួន ។

អ្វីៗដែលគេបានចងដៃនៅពេលនេះ ត្រូវបានជាសម្បត្តិរបស់អ្នកទាំង ២ ។

កាលបើធ្វើពិធីសែនគួចដៃចប់ លោកចាប់ធ្វើពិធីជាបន្តបន្ទាប់

**១. សម័យបុរាណ**

ពីសម័យបុរាណ លោកចាប់ធ្វើពិធីធ្វើធ្មេញ... រហូតដល់ពិធីកប់ល័ក្ត តែម្តង ។

**២. សម័យបច្ចុប្បន្ន**

បើអ្នកមានទ្រព្យ លោកមានធ្វើពិធីកាត់ខាន់ស្លា ផ្នែកខាងចុង តែការធ្វើនោះ មិនមានលក្ខណៈដូចសម័យមុនឡើយ បានន័យថា គ្រាន់តែធ្វើបង្គ្រប់ប៉ុននោះ ។

www.elibraryofcambodia.org

## ៦. ពិធីកាត់ខាន់ស្លា

នៅពេលរៀបអាពាហ៍ពិពាហ៍កូនចៅខ្មែរណាម្នាក់ ដែលមានរៀបពិធីកាត់ខាន់ស្លា លោកអាចារ្យខ្មែរ ត្រូវរៀបធ្វើពិធីនោះ ចាប់ធ្វើពីពិធីក្រាលអង្គររាប ពិធីធ្វើធ្មេញ,... រហូតដល់ពិធីកប់ជីវី ( កប់ល័ក្ខ ) ។

មូលហេតុអ្វី បានជាលោកនាំអោយធ្វើបែបនេះ? ពីព្រោះ

១. ផ្នែកខាងដើម លោកបានបង្ហាញពីទ្រឹស្តី

២. ផ្នែកខាងចុង លោកបានបង្ហាញពីការអនុវត្តតាមទ្រឹស្តី បានផលល្អ ។

**ក. ការបង្ហាញតាមទ្រឹស្តី**

តើមេរៀនទាំងនោះ មានអ្វីខ្លះ?

មានមេរៀនច្រើន តែខ្ញុំលើកយកមេរៀនខ្លះៗ មកបញ្ជាក់

**១. ពិធីក្រាលអង្គរាប**

ជាពិធីបង្ហាញពីពលកម្ម អោយកូនស្រីបានយល់ថា អ្វីៗកើតមានពីពលកម្ម ដែលមានសេចក្តីព្យាយាមល្អ បានន័យថា បើនាងមានប្តី នាងត្រូវលើកភូមិ សង់លំនៅឋានអោយបានល្អសមរម្យ ។ បើនាងលើកភូមិ សង់លំនៅឋានបានល្អហើយ នាងត្រូវជីកស្រះ ជីកអណ្តូងយកទឹកលាយល័ក្ត អោយនាងបៀម ។ បើនាងមិនព្រមជីកស្រះ ជីក

អាណាព្យាបាលខ្មែរដើម្បីការសិក្សា FOUNDATION

www.elibraryofcambodia.org

អណ្ដូង យកទឹកមកលាយល័ក្ដអោយនាងបៀម នាងក៏គ្មានសិរីសួស្ដីកើតមានដល់ខ្លួននាងឡើយ ។

បានន័យថា បើនាងមានទឹកស្រះ ទឹកអណ្ដូង, នាងត្រូវយកទឹកស្រះ ទឹកអណ្ដូងនោះ ទៅស្រោចដំនាំ ដែលនាងបានដាំ។ កាលបើដំនាំនោះ មានដើម មានស្លឹក មានផ្កា មានផ្លែ, សុទ្ធតែកើតមាស កើតប្រាក់ (អប់រំតាមបែបប្រទេសកសិកម្ម) ។

**៦. នៅផ្នែកខាងចុង លោកបានបង្ហាញពីការអនុវត្តតាមច្បាប់ស្រី**

បើនាងមានមាស មានប្រាក់ច្រើន នាងនឹងមានកេរ្តិ៍ឈ្មោះពីរោះល្បីសព្វទីកន្លែង ។

ការមានឈ្មោះពីរោះល្បីនេះ មិនមែនមានឈ្មោះពីរោះល្បីតែម្នាក់ឯងទេ សូម្បីម្ដាយឪពុកខ្លួន ក៏មានឈ្មោះពីរោះល្បីដែរថា កូនលោកនេះ នាងនោះ គេខំរកស៊ីមានទ្រព្យសម្បត្តិច្រើនណាស់ ។

កាលបើនាងមានទ្រព្យសម្បត្តិច្រើន នាងតែងយករឿងនេះទៅជំរាបម្ដាយឪពុកថា ខ្ញុំបានគោរពតាមមេរៀន ដែលលោកមេបា បានយកមកបង្រៀនខ្ញុំ ខ្ញុំបានសំរេចផលល្អខ្ពស់ តាមបំនង ។

ដោយហេតុដែលមានដូចខាងលើនេះហើយ បានជាមានមេរៀនអោយកូនស្រី យកផ្លែឈើផ្សេងៗ មានផ្លែចេកជាដើម និងទឹកអប់

www.elibraryofcambodia.org

ប្រេងម្សៅ ទៅជូនម្តាយឪពុក ហើយនិយាយអួតប្រាប់ម្តាយឪពុកថា ខ្ញុំបានគោរពតាមពាក្យបណ្តាំ ដោយយកចិត្តទុកដាក់ ដំនាំដែលខ្ញុំបានដាំ ដើម, ស្លឹក, ផ្កា, ផ្លែ សុទ្ធតែកើតមាស កើតប្រាក់, ដីភូមិរបស់ខ្ញុំ មានជាតិផ្អែម, ទឹកស្រះ រីអណ្តូង ដែលខ្ញុំបានជីក សុទ្ធតែមានជាតិផ្អែម ។

សូមលោកម្តាយឪពុក ពិសានឹងបានឃើញមាស ប្រាក់ ពិសាដី និងទឹក នឹងបានដឹងថា ដី, ទឹក នោះ មានជាតិផ្អែម ។

**២. ពិធីបុកល័ក្ត**

ជាមេរៀនប្រាប់កូនស្រីតាមបទចំរៀង

កុំអោយខ្ជះខ្ជាយ ត្រូវចេះសន្សំ ទើបចូលទៅនៅក្នុងសង្គមមនុស្សរស់នៅបានល្អ ។

បើនាងបុកល័ក្ត ទទាក់អោយខែ
សន្សំសំចៃ កុំអោយល័ក្តខ្ចាយ ។
បើនាងបុកល័ក្ត កុំបុកបំផាយ
ធ្វើអោយល័ក្តខ្ចាយ ចង្រៃមហិមា ។
លើសកុកទំផ្ទះ រីកធំលលាដ៏
ចង្រៃមហិមា ខ្លាំងណាស់កូនអើយ ។

www.elibraryofcambodia.org

៣. មេរៀន លោកបានបង្ហាញថា

បើនាងធ្វើអ្វីៗ នាងត្រូវចេះសន្សំ ។ បើនាងសន្សំបានហើយ នាងត្រូវចែកតាមចំនែកទីមួយៗ អោយមានតាមផ្នែកៗ តាមការបែងចែកតាមបំនងរបស់ខ្លួន :

| | |
|---|---|
| បើនាងបុកស្រូវ | កុំចោលអង្កាម |
| ចាស់ទុំលោកហាម | អង្កាមទុកលក់ ។ |
| បើនាងបុកស្រូវ | កុំចោលកន្ទក់ |
| ចិញ្ចឹមជ្រូកលក់ | យកមាសយកប្រាក់ ។ |
| ប្រាំតំលឹងទិញសូត្រ | ប្រាំត្រនោតទិញអ័ក្ស |
| ប្រាំទៀនទិញល័ក្ត | ធ្វើធ្មេញប្អូនស្រី ។ |

៤. លោកបង្ហាញអំពីការធ្វើពលកម្ម

ត្រូវរៀនអោយចេះស្ទាត់ ហើយធ្វើការអោយបានម៉ត់ចត់ កុំពឹងលើអ្នកដទៃអោយធ្វើតាមក្រោយ ។ បើនាងធ្វើអ្វីៗ ត្រូវធ្វើអោយបានសំរេចដោយខ្លួនឯង ទើបខ្លួនចូលទៅរស់នៅក្នុងសង្គមមនុស្សបានល្អប្រពៃ ទើបសង្គមមនុស្ស បានអោយតំលៃដល់នាងថា កិច្ចការដែលនាងធ្វើបានល្អ ។

| | |
|---|---|
| បើនាងបុកស្រូវ | បាច់អីម្តាយអុំ |
| ខ្លួនពេញក្រមុំ | ម្តាយអុំដែលៗ ។ |

www.elibraryofcambodia.org

## ៥. មេរៀនទ្រាប់ពីពិធីបៀមល័ក្ត

តាមបទចំរៀងថា

បើនាងបៀមល័ក្ត តាំងចិត្តអំនត់
កំហឹងខុសបទ កំចាត់អោយឆ្ងាយ ។
ចង្រៃគ្រប់មុខ វែងជាប់អន្លាយ
កំចាត់អោយឆ្ងាយ កុំទុកនៅជិត ។
បើនាងបៀមល័ក្ត ត្រូវមានស្នេហ៍ស្និទ្ធ
មនុស្សរស់នៅជិត ជាមិត្តប្រពៃ ។
ទោះរស់នៅឆ្ងាយ ដូចម្ដាយរួមផ្ទៃ
អ្នកផ្ដល់តំលៃ អោយនាងគ្រប់ពេល ។

បើយោងតាមបទចំរៀងខាងលើ លោកបានយល់ថា ធម្មតាមនុស្សណាម្នាក់ បានចូលទៅរស់នៅក្នុងសង្គមមនុស្ស ដែលមានគ្នាច្រើន តែងមានចិត្តគំនិតប៉ះគ្នា ប្រៀបបាននឹងចាននៅក្នុងរាវ ។

ការយល់ឃើញបែបនេះ បានជាលោកយកបទចំរៀងខាងលើមកច្រៀងអប់រំកូនស្រី អំពីការរស់នៅក្នុងសង្គម តែងមានទំនាស់ ។

ដូចនេះ បើនាងចូលទៅរស់នៅក្នុងសង្គមមនុស្ស តែងមានទំនាស់ ។ បើនាងព្រមទៅរស់នៅក្នុងសង្គមមនុស្សច្រើន បើនាងចង់បាន

www.elibraryofcambodia.org

សុខ នាងត្រូវមានអំនត់ធ្មត់អោយបានច្រើន ទើបនាងបានសុខ។ សង្គមមនុស្ស និងបានអោយតំលៃថា នាងជានារីគ្រប់លក្ខណ៍ ។

## បញ្ជាក់ពី
## ពិធីកាត់ខាន់ស្លា

នៅក្នុងសង្គមរបបមាតាធិបតេយ្យខ្មែរ លោកបានបើកឱកាសអោយកូនប្រុស (ទស្សនទានបិតាធិបតេយ្យ របស់ក្រុមចន្ទ្រវង្ស) ដើម្បីស្វែងរកកូនស្រីណា ដែលមានរីកពា មានកិរិយាមារយាទថ្លៃថ្នូរ ចេះថែរក្សាព្រហ្មចារិនីរបស់ខ្លួន អោយបានគង់វង្សល្អ សំរាប់សង្គមមាតាធិបតេយ្យខ្មែរ ទើបលោកយកនារីនោះ មកកាត់ខាន់ស្លា (នេះជាទស្សនាទាន ប្រៀនប្រដៅ ដើម្បីលើកកំពស់ក្រុមសូរិយវង្ស) ។

បើនារីណាមានរីកពា កិរិយាមារយាទមិនល្អ មិនចេះថែរក្សាព្រហ្មចារិនីរបស់ខ្លួន សំរាប់សង្គមរបបមាតាធិបតេយ្យខ្មែរទេ លោកមិនព្រមយកនារីនោះ ទៅកាត់ខាន់ស្លាទេ ថែមទាំងលោកបានបន្ទាបបន្ថោកថា ជានារីចង្រៃបំព្រៃសង្គមរបបមាតាធិបតេយ្យខ្មែរ ថែមទៀត ។

ដូចនេះ មនុស្សនៅក្នុងសង្គមរបបមាតាធិបតេយ្យខ្មែរ ពីសម័យបុរាណ លោកបានយកតែនារីគ្រប់លក្ខណ៍ នៅក្នុងសង្គមខ្មែរ មកកាត់

www.elibraryofcambodia.org

ខាន់ស្លា។ ឯកូនប្រុស លោកមិនបានយកទៅកាត់ខាន់ស្លាឡើយ ពីព្រោះលោកយល់ថា កូនប្រុសនៅក្នុងសង្គមរបបមាតាធិបតេយ្យខ្មែរ លោកបានលែងចោល, លោកមិនដែលបានអោយតំលៃថា ប្រុសគ្រប់លក្ខណ៍ឡើយ ។

នៅសម័យសព្វថ្ងៃនេះ លោកអាចារ្យបានយកកូនប្រុស អោយទៅអង្គុយរួម កាត់ខាន់ស្លាជាមួយនឹងកូនស្រី តើលោកអាចារ្យយល់បែបណា?

ខ្ញុំមានគំនិតយល់ថា ពេលខ្លះ មកពីឪពុកម្តាយនៃកូនស្រីប្រុស អោយធ្វើបែបនេះ។ តែពេលខ្លះ លោកអាចារ្យបាននាំអោយធ្វើបែបនេះដែរ ពីព្រោះលោកអាចារ្យមិនបានយល់ពីរបបមាតាធិបតេយ្យខ្មែរដែរ ។

**គត់ចំណាំ:** បើមាតាបិតាទាំងសងខាង លោកបង្ខំអោយធ្វើ គួរលោកអាចារ្យពន្យល់វិញថា ការអោយកូនប្រុសចូលទៅអង្គុយកាត់ខាន់ស្លាជាមួយនឹងកូនស្រី មិនត្រូវតាមរបបមាតាធិបតេយ្យខ្មែរទេ ។

ម្យ៉ាងទៀត បើយកកូនប្រុសទៅកាត់ខាន់ស្លា តើអោយអ្នកណាជាអ្នកចេញប្រាក់ថ្លៃខាន់ស្លា រឺក៏នាំគ្នាធ្វើរបៀបលេង?

បើនាំគ្នាធ្វើរបៀបលេងទេ គួរកុំធ្វើល្អជាង កុំអោយគេធ្វើតាម នាំអោយខូចតំលៃរបបមាតាធិបតេយ្យខ្មែរ ។

www.elibraryofcambodia.org

ពីសម័យបុរាណ សូម្បីស្រីដែលមានរឹកពាមិនល្អ បានឃើញប្រុសនិយាយឡេះឡោះច្រើន មិនគប្បីភ្នែកអ្នកដទៃមើល ក៏គេមិនយកស្រីបែបនេះទៅកាត់ខាន់ស្លាដែរ ។

បន្តពីនេះទៅ ខ្ញុំសូមលើកយកប្រពៃណី ពីរបៀបធ្វើពិធីកាត់ខាន់ស្លា ពីសម័យបុរាណដោយសង្ខេបខ្លីៗ មកជំរាបជូន :

- បើលោកបានរៀបក្រាលអង្គរវាបរួចហើយ លោកមេបាបានបញ្ជាអោយអ្នកភ្លេង ច្រៀងហៅកូនស្រីចេញមកអង្គុយលើអង្គរវាបថា

ស្រីសត្រឡុង ចេញមកពីក្នុង
មកអង្គុយលើអង្គរវាប ។
ស្រីសសុភាព មកអង្គុយលើអង្គរវាប
បំពេញលក្ខណ៍ស្រី[១] ។

លុះចប់ពិធីធ្វើធ្មេញ ចូលដល់ពិធីកាត់ខាន់ស្លា លោកមេបា បានបង្គាប់អោយភ្លេង ច្រៀងអញ្ជើញព្រះមាតាបិតាកូនស្រី អោយមកអង្គុយបាំងឆត្រអោយកូនស្រី ដែលនាងកំពុងអង្គុយលើអង្គរវាបស្រាប់[២] ។

---

១. អាពាហ៍ពិពាហ៍ខ្មែរ ភាគ ២ ទំព័រ ២៨

២. អាពាហ៍ពិពាហ៍ប្រៀបធៀបភាគ ១ ទំព័រ ១០៦ បន្ទាត់ ១២

www.elibraryofcambodia.org

រូបអន្ទូយកាត់ខាន់ស្លា



រូបនេះ ខ្ញុំបានពីកញ្ញា ស៊ុន សុវណ្ណនី

ដែលអង្គការពិពរណ៌វប្បធម៌អង្គរព្យុខយូ បានធ្វើនៅខេត្តសៀមរាប

ពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៦

www.elibraryofcambodia.org

## ក៏.សំ នៅក្នុងពិធីកាត់ខាន់ស្លា

តើការអង្គុយបាំងឆ័ត្រនាំអោយមានអ្វី? នាំអោយមានម្លប់ ។ តើម្លប់នាំអោយមានអ្វី? នាំអោយបានត្រជាក់កាយសប្បាយចិត្ត ព្រោះមានទីពឹង ។ តើម្លប់ជាតំនាងអ្វី? តំនាងព្រហ្មវិហារធម៌ ។

តើកូនមានព្រហ្មវិហារធម៌លើម្តាយឪពុកទេ?

បើយោងតាមទ្រឹស្តីព្រះពុទ្ធសាសនា កូនមិនមានព្រហ្មវិហារធម៌លើម្តាយឪពុកទេ មានតែកតញ្ញូតាធម៌ ចំពោះម្តាយឪពុកវិញ ។

ចុះម្តាយឪពុក មានព្រហ្មវិហារធម៌លើកូនទេ? ម្តាយឪពុក មានព្រហ្មវិហារ ៤ គឺមេត្តា ករុណា មុទិតា ឧបេក្ខា លើកូន ។

ចុះសព្វថ្ងៃនេះ ខ្ញុំបានឃើញលោកអាចារ្យ ហៅកូនស្រីប្រុសអោយទៅបាំងឆ័ត្រជូនម្តាយឪពុក តើត្រូវទេ?

ខ្ញុំឆ្លើយថា តើនរណា ជាអ្នករៀបការអោយនរណា? ខ្ញុំបានដឹងច្បាស់ថា ម្តាយឪពុក ជាអ្នករៀបការកូន មិនមែនកូនជាអ្នករៀបការជូនម្តាយឪពុកទេ ។

ម្តាយឪពុក ជាអ្នកឈររៀបការកូននេះហើយ ដែលលោកបានតំលៃថា ព្រហ្មវិហារធម៌ ។ បើគ្មានព្រហ្មវិហារធម៌ទេ មិនអាចឈររៀបការកូនបានឡើយ ។

www.elibraryofcambodia.org

បើដូចនេះ តើនរណា ត្រូវអង្គុយបាំងអោយអ្នកណា?

បើយោងតាមទ្រឹស្តីព្រះពុទ្ធសាសនាក្តី ប្រពៃណីខ្មែរក្តី ត្រូវម្តាយឪពុក ជាអ្នកឈររៀបការកូន ត្រូវម្តាយឪពុកអង្គុយបាំងឆ័ត្រអោយកូន ដើម្បីសំដែងព្រហ្មវិហារធម៌អោយកូនបានដឹងថា ម្តាយឪពុកត្រូវមានព្រហ្មវិហារធម៌លើកូន រហូតដល់ខ្លួនស្លាប់ ។

ដូចនេះ ពីសម័យបុរាណ កាលបើលោកបានរៀបពិធីក្រាលអង្គររាបហើយ លោកមេបាបានបង្គាប់អោយអ្នកភ្លេង ច្រៀងហៅកូនស្រីទៅអង្គុយលើអង្គររាប ។

លុះចប់ពិធីធ្វើធ្មេញ លោកមេបាបានបញ្ជាអ្នកភ្លេង ច្រៀងអញ្ជើញមាតាបិតាកូនស្រី មកអង្គុយបាំងឆ័ត្រអោយកូនស្រី ដែលនាងកំពុងអង្គុយលើអង្គររាបស្រាប់ ។

លុះលោកអាចារ្យក្តី អ្នកច្រៀងកាត់ខាន់ស្លាក្តី បាននិយាយ និងច្រៀងអប់រំកូនស្រីចប់ ទើបលោកមេបា បានបង្គាប់អ្នកច្រៀងហៅកូនប្រុស មកចុះកិច្ចសន្យា ៥ ខ ថា បើកូនស្រីរបស់ខ្ញុំជាមេបា បានធ្វើកិច្ចអ្វីមានការឆ្គាំឆ្គង ព្រោះនាងជាស្រី មានភាពក្មេងខ្ចី អ្នកត្រូវពន្យល់ណែនាំអោយនាងយល់ អ្នកកុំធ្វើអំពើអមនុស្សធម៌ចំពោះនាង ៖

១. កុំជេរម្តាយតាយឪពុក ប្រដូចដល់ញាតិសន្តាន

www.elibraryofcambodia.org

២. កុំវាយក្បាលនឹងកន្ទុយអុស

៣. កុំវាយក្បាលនឹងអំបោស

៤. កុំវាយក្បាលនឹងស្បែកជើង

៥. បើអ្នកបានបំពានលើ ខ ទាំង ៤ ខ ណាមួយ ខាងលើនេះហើយ ខ្ញុំជាមេបា នឹងរឹបអូសយកទ្រព្យសម្បត្តិដែលមានទាំងប៉ុន្មាន មកប្រគល់អោយកូនស្រីទាំងអស់។ ឯខ្លួនអ្នក ត្រូវចុះពីផ្ទះតែខ្លួនទទេ ។

កាលបើលឺកិច្ចសន្យាទាំង ៥ ខ នេះ លោកមហា មាតាបិតាចាស់ទុំ នឹងសាមីខ្លួនកូនប្រុស ឆ្លើយព្រមគ្នាថា យើងខ្ញុំទាំងអស់គ្នាយល់ព្រមទទួលដោយសេចក្តីរីករាយ ។

លោកមេបា មាតាបិតា ញាតិខាងកូនស្រី បានយល់ព្រមអោយកូនស្រី ចេញទៅអង្គុយសំពះផ្ទឹមជាមួយនឹងកូនប្រុស ។

បានន័យថា កូនស្រីនៅក្នុងរបបមាតាធិបតេយ្យខ្មែរ មានតំលៃខ្លួនខ្ពស់ណាស់ ។

លុះធ្វើពិធីកាត់ខាន់ស្លាបានចប់ស្រេចបាច់ហើយ ទើបលោកមេបាបង្គាប់អោយធ្វើពិធីកប់ជីវីទៀត ។

www.elibraryofcambodia.org

# ពិធីកប់ជីវ៍ (កប់លក្ខ)

## តើពិធីកប់លក្ខបែបណា?

បើមេបាបង្គាប់អោយកប់កន្លែងណា គេត្រូវជីករណ្តៅនៅកន្លែងនោះ មានជំរៅ ១ លូក ទើបគេអោយកូនស្រី យកកន្ទោងលក្ខទៅដាក់ក្នុងរណ្តៅ ហើយបញ្ជាអោយកូនស្រីកាយអាចម៌ដីកប់ ជាន់អោយជិត កុំអោយធំក្លិនចេញមកក្រៅ ។

**បញ្ជាក់**

ឯកសារនេះ ខ្ញុំចំលង និងកែសំរួលចេញពីកាសែតចំរៀងកាត់ខាន់ស្លា លោកតា **នួន** ម៉ៅ នៅភូមិស្នាយរាន ឃុំបឹងព្រះ ស្រុកបាភ្នំ ព្រៃវែង ។

**កំនត់សំគាល់**

- សៀវភៅអាពាហ៍ពិពាហ៍ខ្មែរ ភាគ ១-២ ខ្ញុំបានបោះពុម្ពនៅឆ្នាំ ១៩៩៥
- អង្គការពិពរណ៍វប្បធមិអង្គរឃ្សុងឃូ រៀបពិធីអាពាហ៍ពិពាហ៍នៅឆ្នាំ ២០០៦
- ស្រុកបាភ្នំ និងខេត្រសៀមរាប ឆ្ងាយពីគ្នាណាស់
- លី សុវីរ និងលោកអាចារ្យ ពិន សឿន មិនដែលស្គាល់គ្នា
- រយះពេលខុសគ្នាឆ្ងាយ

www.elibraryofcambodia.org

- ម្តេចសៀវភៅអាពាហ៍ពិពាហ៍ខ្មែររបស់ខ្ញុំ និងកាសែតរបស់អង្គការពិពរណ៍វប្បធមិឃ្យុងយូ ដូចគ្នាម៉្លេះ គ្រាន់តែសៀវភៅរបស់ខ្ញុំ កូនស្រីបានអង្គុយនៅលើអង្គរវាប ម្តាយឪពុកកូនស្រី អង្គុយបាំងឆ័ត្រ អោយកូនស្រី។ ឯការសែតអង្គរឃ្យុងយូ អង្គុយនៅកន្លែងស្មើគ្នាប៉ុននោះ ពីព្រោះគ្មានរៀបធ្វើអង្គរវាប ។

ក្រែងប្រពៃណីពិធីកាត់ខាន់ស្លារបស់ខ្មែរ មានលក្ខណៈបែបនេះទេដឹង ?

សូមពិចារណា!

ពីព្រោះ ជាប្រពៃណី នៃជនជាតិទាំងមូល

មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION

## ច. ពិធីលាងជើង

នៅក្នុងពិធីអាពាហ៍ពិពាហ៍កូនចៅខ្មែរ, បុព្វបុរសខ្មែរ លោកបានបង្កើតពិធីតូច១ ជាច្រើន, ប៉ុន្តែពិធីតូច១ទាំងនោះ ខ្ញុំសូមលើកយកពិធី ៣ គឺ ពិធីលាងជើង, ពិធីសំពះផ្ទឹម និងពិធីគោងស្បៃ មកពិភាក្សា, ពិចារណា អោយតំលៃថា តើពិធីទាំង ៣ នេះ កើតមានពីសម័យណា?

បើយោងតាមការស្រាវជ្រាវ ឃើញថា កើតមានតាំងពីបរមបុរាណ គឺមុនសម័យរៀបរាជាភិសេកព្រះថោង នាងនាគ រឺពីសម័យ

www.elibraryofcambodia.org

រាជាភិសេកព្រះបាទ ហ៊ុន ទៀន និងព្រះនាង លីវ យី ជាបឋម ព្រះមហាក្សត្រខ្មែរជាស្ត្រី មកម៉្លេះផង ។

បើគិតពីសម័យនោះ មកដល់សម័យបច្ចុប្បន្ន ឆ្នាំ ២០១២ នេះ អស់រយៈពេលច្រើនជាង ២០០០ ឆ្នាំមកហើយ ។

ខ្ញុំឆ្ងល់ថា នៅពេលរៀបការ យាយយើង តាយើង, ម៉ែយើង ឪយើង តើមានយាយណា ម៉ែណា មិនព្រមលាងជើងអោយតាយើង ឪយើងទេ? តើមានតាណា ឪណា មិនព្រមតោងស្បៃយាយយើង ម៉ែយើងទេ?

បើតាមឯកសារនានា មិនឃើញមានប្រាប់, តាមពាក្យបរមបរា ក៏មិនដែលមាននិយាយ។ ឯពិធីរៀបការកូនចៅ ចេះតែមានបន្តរៀង រហូតមក ហើយបានរស់នៅស្ងប់ស្ងៀម ដោយសុខដុមរមនា ជាមួយគ្នា ដោយសប្បាយរីករាយផង អស់ជាង ២ ០០០ ឆ្នាំហើយផង ។

**ទស្សនទានស្នេហ**

ចាប់បន្តពីសង្គម ប៉ុល ពត មក ខ្ញុំមានការព្រួយបារម្ភច្រើន ណាស់ ខ្លាចប្រពៃណីខ្មែរ រអិលធ្លាក់ខុសផ្លូវពីអរិយធម៌ខ្មែរបុរាណ ។

មូលនិធិខ្មែរសម្រាប់ការសិក្សា FOUNDATION

www.elibraryofcambodia.org

ការព្រួយបារម្ភនេះ ធ្វើអោយខ្ញុំខំស្រាវជ្រាវ រកឯកសារប្រពៃណីអាពាហ៍ពិពាហ៍ខ្មែរ ទោះគេយល់តាមក្តី គេមិនយល់តាមក្តី ខ្ញុំត្រូវសរសេរសៀវភៅ ពិធីអាពាហ៍ពិពាហ៍កូនចៅខ្មែរ មាន

១. អាពាហ៍ពិពាហ៍ខ្មែរ ភាគ ១, ២

២. អាពាហ៍ពិពាហ៍ប្រៀបធៀប ភាគ ១,២

៣. ពិធីហៅព្រលឹង ដែលមាននិយាយទាក់ទង នឹងអាពាហ៍ពិ-ពាហ៍ខ្មែរ ។

៤. អាពាហ៍ពិពាហ៍ កំពុងមានវិបល្លាស

៥. អាពាហ៍ពិពាហ៍បន្ថែម ស្តីពីពិធីកាត់ខាន់ស្លា និង

៦. អាពាហ៍ពិពាហ៍បង្គ្រប់ កំពុងសរសេររើសយកបញ្ហាណា ដែលមានទំនាស់នៅក្នុងសង្គមខ្មែរ យកមកសរសេរដោះស្រាយ ។

ខ្ញុំសូមសំនូមពរ លោកអ្នករៀបចំ ពីពិធីអាពាហ៍ពិពាហ៍កូនចៅខ្មែរថា យើងអ្នកដឹកនាំពិធីអាពាហ៍ពិពាហ៍ មិនមែននឹកឃើញហើយថាទេ។ បើនឹកឃើញហើយ ត្រូវយកគំនិតនោះ មកពិភាក្សា ថ្លឹងថ្លែងពិចារណា អោយបានច្បាស់ ទើបយកគំនិតនោះ មកប្រាប់គេអោយអនុវត្តតាម ។

www.elibraryofcambodia.org

ប្រសិនបើគំនិតនោះ មិនទាន់មានការឯកភាពគ្នាទេ កុំយកមកនិយាយ ម្តងថាបែបនេះ ម្តងថាបែបនោះ ធ្វើអោយគេអស់ជំនឿលើខ្លួនផង លើឯកសារនានាផង ។

បន្តពីនេះទៅ ខ្ញុំសូមលើកយកបញ្ហានារី ដែលមិនព្រមលាងជើងអោយបុរស តើមកពីមូលហេតុអ្វី?

យើងបានរៀនពីអរិយធម៌ខ្មែរ យល់បញ្ហារបស់ខ្លួនអោយបានច្បាស់សិន លុះអរិយធម៌របស់គេចូលមក ខ្លួនកុំចេះតែទទួលយកដោយគ្មានការពិចារណា ។

ឧទាហរណ៍ នៅសម័យដើមសតវត្សទី ២០ នេះ ប្រុសខ្មែររត់មុខរទេះ មិនប៉ាន់ទទូរក្រមា ពីចំនួន ២ ឆ្នាំ ទៅ ៤ ឆ្នាំ ទើបបាននារីខ្មែរម្នាក់ យកមកធ្វើជាប្រពន្ធ ។

ឯប្រទេសអឺរ៉ុបវិញ នៅសម័យនោះ ស្រីជាទាសកាមគុណរបស់ប្រុស ។ លុះស្រីអឺរ៉ុបគេខំរើបំរាស់ ទាមទារយកសិទ្ធិអោយស្មើនឹងបុរសបាន ។ ឯនារីខ្មែរយើង ក៏ខំប្រឹងស្រែកទាមទារយកសិទ្ធិខ្លួន អោយស្មើនឹងបុរស ដូចជានារីអឺរ៉ុបដែរ ។

ខ្ញុំឆ្ងល់ ខ្ញុំសួរថា នារីខ្មែរ និងបុរសខ្មែរ តើនរណាធំជាងនរណា? នៅពេលបច្ចុប្បន្ននេះ ។

www.elibraryofcambodia.org

នារីខ្មែរ បើនារីណាឆ្លើយថា នារីមានសិទ្ធិតិចជាងបុរសឆ្ងាយណាស់។ សូមអោយនារីនោះ ទៅដណ្ដឹងប្រុស អោយប្រុសបង្គាប់ប្រាក់ខាន់ស្លា ប្រុសបង្គាប់ទេយ្យវត្ថុជាជំនូន, ទារយកប្រាក់ស្នាប់ទឹកដោះពីនារីវិញ ទើបត្រូវ ។

តែសព្វថ្ងៃ ខ្ញុំនៅតែឃើញប្រុស ស្ដីដណ្ដឹងស្រី បង្គាប់ប្រាក់ខាន់ស្លា ថ្លៃស្នាប់ទឹកដោះពីប្រុស រឺម្ដាយឪពុកប្រុស ម្ដេចក៏ថា នារីមានសិទ្ធិតិចជាងបុរស ។

ដូចនេះ ស្រីធំជាងប្រុស តើនារីទាមទារយកអ្វីទៀត? ចង់បានធំជាងប្រុសបែបណាទៀត?

មូលនិធិខ្មែរសម្រាប់ការសិក្សា FOUNDATION

## ក. ពិធីលាងជើង

បើនាងគិតត្រឹមតែ លាងជើងជំរះដីធូលី ដែលមានជាប់នៅជើងប្រុស អោយស្អាត កុំអោយឡើងទៅលើផ្ទះ ខ្លាចប្រលាក់កន្ទេល, កំរាល តាមន័យអត្ថានុរូប គួរថាទាបថោកទៅចុះ! ចុះបើពិធីលាងជើងនៅក្នុងអាពាហ៍ពិពាហ៍ខ្មែរ ពីសម័យមុននេះបន្តិច គេហែកូនប្រុសពីរោងផ្កាស្លា មកដល់ជើងជណ្ដើរផ្ទះកូនស្រី ឈរយេប់លើថ្មដា រឺនៅលើគល់ឈើ ។

www.elibraryofcambodia.org

កូនស្រីចុះពីលើផ្ទះ កាន់យកផ្តិលទឹកមកលាងជើងកូនប្រុស។ លុះលាងរួច កូនស្រីជូនស្លាមួយម៉ាត់ទៅកូនប្រុស។ កូនប្រុសជូនប្រាក់ ១ រៀល រឺ ២ រៀលទៅកូនស្រីវិញ តាមលទ្ធភាព ។

បើគិតតាមន័យអត្ថានុរូប ហាក់ដូចជាស្រីទាបថោកមែន។ តែបើនាងគិតតាមន័យអត្ថប្បដិរូបវិញ បានន័យថា លាងជំរះអំពើក្បត់ប្រពន្ធ ដូចជាមានប្រពន្ធហើយ ទៅមានប្រពន្ធលួចលាក់ ២, ៣ ទៀត, ដើរផឹកស្រា, លេងបៀរ ប៉ោឡែ ចោលប្រពន្ធ-កូន ។

តើនាងធំ រឺតូច? បើនាងតូច គេមិនបាច់រៀបពិធីទេ។ បើនាងតូច តើនាងហ៊ានអប់រំប្តី កុំអោយធ្វើអំពើក្បត់នានាទេ?

គ្រាន់តែបុព្វបុរសខ្មែរ បានធ្វើអោយនាងធំ តាមរបៀបស្រីគ្រប់លក្ខណ៍។ នាងអប់រំប្តី តាមភាសា, កិរិយា, ចរិយា ជានារីគ្រប់លក្ខណ៍ នាងមិនជេរពោល រោលពត់ អាមឹង តាមបែបនារីខាតលក្ខណ៍ឡើយ។

## ខ. ពិធីគោចស្បៃ

តាមន័យអត្ថានុរូប យើងបានឃើញកូនប្រុស ដើរអោនគោងស្បៃនាង ពីក្រោយមែន។ តែបើតាមន័យអត្ថប្បដិរូបវិញ បានន័យថា កូនប្រុស ត្រូវធ្វើអ្វីតាមស្រីយល់ឃើញផងដែរ, បើរកទ្រព្យសម្បត្តិបាន

www.elibraryofcambodia.org

មក ត្រូវប្រគល់អោយស្រីជាអ្នកទុកដាក់ ចាត់ចែង សន្សំទុកផង,... មើលរឿងមាយើង ។

បើចាស់ៗ និយាយលេង បែបកំប្លែងថា អា! កុំរស់នៅក្រោមកន្ទុយក្បិនកូនស្រីពេក បានន័យថា តោងស្បៃ គឺតោងកន្ទុយក្បិនប្រពន្ធទៅវិញ ។

សូមនាងថ្លឹងថ្លែង វិភាគពិចារណា លើពិធី អាពាហ៍ពិពាហ៍ខ្មែរ ដែលបុព្វបុរសខ្មែរ បានបង្កើត តើមានពិធីណាមួយ បានធ្វើអោយស្រីទាបថោក បើមានសូមប្រាប់ខ្ញុំជាអ្នកនិពន្ធវិញផង ។

បើតាមទស្សនៈអ្នកនិពន្ធវិញ ខ្ញុំថាគ្មានទេ ។

បើមានពិធីណាមួយ ធ្វើអោយថោកទាប លោកមិនបានអោយតំលៃថា របបមាតាធិបតេយ្យខ្មែរឡើយ ។

សូមលោកអ្នកអានទាំងអស់ បើយល់ថាខុស រឺថាត្រូវ សូមធ្វើអត្ថបទចំនាប់អារម្មណ៍ខ្លីមួយ ប្រគល់អោយខ្ញុំ, ខ្ញុំនឹងយកអត្ថបទនោះទៅចុះក្នុងសៀវភៅ អាពាហ៍ពិពាហ៍បង្រួប ទុកជាអត្ថបទចំនាប់អារម្មណ៍ របស់លោក សំរាប់ទុកអោយជាតិខ្មែរ បានយល់ទៅថ្ងៃក្រោយ ។

www.elibraryofcambodia.org

**បញ្ជាក់**

- នៅទសវត្សទី ៩ ទី ១០ និងទី ១ នៃសតវត្សទី ២០ និងទី ២១ នេះ កូនប្រុសបានពាក់ស្រោមជើង ពាក់ស្បែកជើងឃ្លប់ ឡើងទៅដល់លើផ្ទះកូនស្រី ទើបដោះស្បែកជើងឃ្លប់ចេញ នៅពាក់ស្រោមជើងទៅឈរជាន់នៅលើថ្មដា ដែលគេតំកល់លើកំរាលព្រំដ៏ល្អប្រពៃ គួរជាទីស្រលាញ់ ។

- កូនស្រីចេញពីក្នុងបន្ទប់ កាន់យកដបទឹកអប់មកបាញ់លើជើងកូនប្រុស រួចយកសំលី រឺកូនកន្សែងសល្អស្អាត ទៅត្របលើជើងកូនប្រុសមួយសន្ទុះ ទើបក្រោកឈរឡើង ហុចជាយកន្សែងទៅអោយកូនប្រុសដើរតោងជាយកន្សែង ដើរជិតដល់កំរាលកន្លែងសំពះផ្ទឹម កូនប្រុសលែងជាយកន្សែង, កូនស្រីចូលទៅក្នុងបន្ទប់របស់ខ្លួនវិញ។ ឯកូនប្រុស បានចូលទៅអង្គុយលើកំរាលសំពះផ្ទឹម ។

- អ្នកច្រៀងបើកវាំងនន ទៅឈរច្រៀងនៅមុខបន្ទប់កូនស្រីអញ្ជើញអោយកូនស្រី ចេញមកសំពះផ្ទឹមជាមួយនឹងកូនប្រុស ។

តើកូនស្រីលោកចង់បានអ្វី? រឺលោកចង់ជំរះអ្វី?

+ បើចង់ជំរះធូលី ជើងនៅទាំងស្រោម គ្មានធូលីជាប់នឹងជើង, មានតែលាងជំរះអំពើក្បត់នានា រឺគំនិតពាលាអាវ៉ាសែ អោយចេញ

www.elibraryofcambodia.org

ឆ្ងាយពីខ្លួនកូនប្រុស អោយនៅសល់តែក្លិនក្រអូប បានន័យថា នៅសល់តែការប្រព្រឹត្តអំពើល្អ គឺក្លិនក្រអូបនេះឯង ។

ឯក្លិនក្រអូបទឹកអប់ បានឆ្ងាយណាស់ បានត្រឹមជាង ២ ម៉ែត្រ។ ឯក្លិនក្រអូបនៃការប្រព្រឹត្តល្អរបស់បុរស ស្ត្រីវិញ មានក្លិនក្រអូបមានចំងាយរាប់រយ រាប់ពាន់គីឡូម៉ែត្រ ។

+ បើមិនលាងជើងវិញ វាមានន័យថា ទុកបណ្តោយអោយកូនប្រុស នៅតែរក្សាទុកនូវគំនិត និងអំពើខុសឆ្គងពីមុនមកដាក់ក្នុងគ្រួសារ ហើយកូនស្រី ត្រូវតែសុខចិត្តទទួលយកដោយស្ងៀមស្ងាត់វឹ?

**បញ្ជាក់**

មូលនិធិខ្មែរសម្រាប់ការសិក្សា

ពិធីលាងជើង ពិធីសំពះផ្ទឹម ពិធីតោងស្បៃ ពិធីទាំង ៣ នេះត្រូវមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត បានន័យថា បើកូនប្រុស យល់ព្រមអោយកូនស្រីលាងជើង។ លុះដល់ពេលសំពះផ្ទឹម ទើបកូនស្រីយល់ព្រមចូលទៅអង្គុយសំពះផ្ទឹមរួមខ្នើយ កូនប្រុសបានឃើញកូនស្រីបំពេញតួនាទីជានារីគ្រប់លក្ខណ៍ ទើបកូនប្រុសក្រោកឈរតោងស្បៃកូនស្រី រហូតដល់ក្នុងបន្ទប់ ។

ការធ្វើតាមការយល់ឃើញបែបខាងលើនេះ ទើបកូនចៅខ្មែរបានសុខចំរើន អស់យាវជីវ ។

បើធ្វើពិធីលាងជើងរួច ត្រូវរៀបធ្វើពិធីសំពះផ្ទឹមបន្តទៀត ។

## ឆ. សូមរិះគន់ស្ថាបនា ចំពោះអ្នករៀបពិធី

ខ្ញុំសូមអភ័យទោស ពីសំនាក់លោកអ្នករៀបកែតំរូវពិធី អាពាហ៍ពិពាហ៍ខ្មែរថា បើយើងធ្វើត្រូវ គេធ្វើតាមហើយ មិនបាច់ដើរបន្លាចគេថា បើមិនធ្វើបែបនេះ បែបនោះទេ និងលក់ផ្ទៃ។ តែបើយើងធ្វើខុសវិញ បើទុកជាយើងដើរបន្លាចគេយ៉ាងណាក៏ដោយ ក៏គេមិនធ្វើតាមដែរ ។

+ ពិធីអាពាហ៍ពិពាហ៍ ជាច្បាប់ ជាប្រពៃណីខ្មែរទេ បើមានការមិនគោរពអនុវត្តតាម គឺមិនមានថែងអំពីផ្ទៃ វិពិន័យនោះទេ តែគឺត្រូវអប់រំគេ ដែលវាខុសពីទំរង់ច្បាប់ជាតិបច្ចុប្បន្ន គឺអាចផ្ទៃ ដាក់ទណ្ឌកម្មណាមួយនោះ ក៏ត្រូវតែអនុវត្តច្បាប់ប្រព័ន្ធហិរញ្ញវត្ថុដែរ តើយកប្រាក់ផ្ទៃនោះទុកឯណា?

www.elibraryofcambodia.org

+ ករណីមួយទៀត ជាឧទាហរណ៍ នៅក្នុងពិធីរាំបើកទៀប ច្បាប់ដើមនៅគ្រប់ឯកសារ លោកដាក់ថា រាំបើកបាយស្រី។ ឯលោកអ្នកច្រៀង លោកបានច្រៀងថា រាំបើកបាយប្រស្រី[៣] ។

**ខ្ញុំឆ្ងល់**

- តើបាយ មានប្រស្រី ដែររឺ?

- បើអ្នកភ្លេងច្រៀងខុស គួរអ្នករៀបពិធី ប្រាប់អ្នកច្រៀងថា មិនមែនបាយប្រស្រីទេ ពាក្យត្រូវលោកហៅថា បាយស្រី ។

- អ្នករៀបពិធី អង្គុយនៅព័ទ្ធជុំវិញត្រៀបត្រា គ្មានអ្នករៀបពិធីណាម្នាក់ ប្រាប់អ្នកច្រៀង អោយកែពាក្យបាយប្រស្រី មកជាពាក្យបាយស្រី វិញឡើយ។ ពាក្យបាយប្រស្រី នៅតែមានច្រៀងរហូតមកដល់ខែ ៦ ឆ្នាំ ២០១២ នេះ ។

ខ្ញុំយល់ថា បើគ្មានអ្នករិះគន់ទេ នៅតែមិនដឹងខុស! បើមិនកែពាក្យបាយប្រស្រីទេ ពាក្យនេះបានរស់ទាំងទទឹងទិស ធ្វើអោយក្លាយន័យដើម ពីព្រោះ គេនាំគ្នាធ្វើតាម នឹងក្លាយជាប្រពៃណីឆ្គួតលីលា ។

---

៣. បាយស្រី<បាយសិរី បាលី, បាយស្រី សំស្ក្រឹត គឺបាយដែលគេបានហូបហើយ ធ្វើអោយអ្នកហូប មានសេចក្ដីសុខចំរើន ។

www.elibraryofcambodia.org

រឺអ្នករៀបពិធី មិនបានចេះ មិនបានដឹង ពាក្យនេះផងទេដឹង?

បើអ្នករៀបពិធី មិនចេះពាក្យបាយស្រីនេះទេ, សូមលោកមើលក្បួនអាពាហ៍ពិពាហ៍ មហាមន្ត្រី ញ៉ូក នូវ ទំព័រ ១៦២ រឺមើលពាក្យបាយស្រី នៅក្នុងវចនានុក្រមខ្មែរ ទំព័រ ៥៦៧ ស្តាំ ។

តើមានមូលហេតុអ្វី បានជាលោកហៅថា បាយស្រី ពីព្រោះ នៅក្នុងពិធីមង្គលការពីសម័យបុរាណ មានធ្វើពិធីហៅព្រលឹង នៅក្នុងពិធីធ្វើធ្មេញ។ ពិធីហៅព្រលឹងនោះ មានពិធីដាំបាយព្រលឹង ។

តើពិធីដាំបាយព្រលឹងនោះ គេធ្វើបែបណា? គេយកអង្ករដំនើបសុទ្ធល្អ ទៅលាងអោយស្អាតល្អ គេដាក់សំដិលអោយស្ងួតល្អ ។

គេកាប់ដូងខ្ចីចំនាស់បន្តិច ពីខាងគូទ គេកាប់ចោះធ្វើជាគំរប។ គេបញ្ចូកអង្ករនោះ ទៅក្នុងដូងអោយពេញ។ គេយកដូងទៅដាក់លើចង្ក្រាន។ គេយកអុសគរដុតដូងនោះ រហូតដល់បាយជិតឆ្អិន ។

ទើបគេយកដូងនោះ មកបើកគំរប គេចាក់ខ្ទិះដូង, ទឹកដោះគោ, សណ្តែក, ល្ង ដែលគេបានលីងឆ្អិនល្អហើយ ខ្លះគេបុក ខ្លះគេដាក់ទាំងមូល ទៅក្នុងបាយនោះ, គេកាយជ្រោយអោយសព្វ ទើបគេយកដូងនោះ ទៅដាក់លើចង្ក្រាន ដុតភ្លើងភ្ញំបាយម្តងទៀត ធ្វើអោយបានឆ្អិនល្អ ។

www.elibraryofcambodia.org

លុះភ្ញំបាយបានឆ្អិនល្អហើយ គេដួសយកបាយ ១ ស្លាបព្រា រឺ ៣ ស្លាបព្រាចេញពីក្នុងដួង មកអោយកូនស្រីហូប នៅពេលដែលលោកអាចារ្យធ្វើពិធីហៅព្រលឹងចប់ ។

ឯបាយព្រលឹងដែលសល់នៅក្នុងដួង លោកដួសដាក់តៀប ទុកយកទៅអោយកូនស្រី-ប្រុសហូប នៅក្នុងពិធីផ្សំដំនេក ។

**បញ្ជាក់**

នៅក្នុងអាពាហ៍ពិពាហ៍ពីសម័យបុរាណ លោកប្រើតៀប ៣ គឺ តៀប ១ សំរាប់ដាក់បាយព្រលឹង ទុកអោយកូនស្រី-ប្រុសហូប នៅពេលរៀបពិធីផ្សំដំនេក។ ឯតៀប ២ ទៀត លោកដាក់នំចំនី, មាន់ស្ងោ, សាច់ជ្រូក ផ្សេងទៀត ទុកជូនអ្នករាំបើកបាយស្រី ។

**នៅពេលរាំបើកតៀប**

គេដាក់តៀបបាយព្រលឹងនៅកណ្ដាល, ឯតៀប ២ ទៀត នៅអមសងខាង។ អ្នកច្រៀងបើកតៀប លោកយកតែតៀបសងខាង, ឯតៀបកណ្ដាល លោកទុកជូនកូនស្រី-ប្រុស ។

**មូលហេតុអ្វី បានជាលោកប្រើតៀប ៣ ?**

**ម្ដេចបច្ចុប្បន្ន នៅតែតៀប ២ វិញ ?**

បើយោងតាមប្រពៃណីខ្មែរ, បើលោកបង្កើតអ្វីៗ លោកបានគោរពតាមគោលការណ៍ ៤ គឺ ៣, ៥, ៧, ៩ ។

www.elibraryofcambodia.org

**សូមពិនិត្យមើលកាំជណ្តើរផ្ទះខ្មែរបុរាណ :**

បើផ្ទះលោកទាប លោកធ្វើជណ្តើរមានកាំមួយ ។

បើផ្ទះលោកខ្ពស់បន្តិច លោកធ្វើជណ្តើរមានកាំ ៣, ៥, ៧, ៩។ បើផ្ទះនោះខ្ពស់ លោកធ្វើជណ្តើរបត់ចុះ បត់ឡើង, ធ្វើយ៉ាងណា អោយជណ្តើរនោះ មានកាំ ៣, ៥, ៧, ៩។ ឯជណ្តើរមានកាំ ៩ មិនឃើញមាននៅសល់ ។

**សង្កេតតាមឯកសារនានា**

បើសង្កេតតាមឯកសារនានាឃើញថា ខ្មែរពីសម័យបុរាណ លោកបានគោរពតាម

- បារ៉មី ៥ : មេ, បា, ព្រះ, តា, ចារ ។

តែក្រោយមក ប្រហែលជានៅក្រោយសម័យព្រហ្មញ្ញសាសនា វីព្រះពុទ្ធសាសនាចូលស្រុកខ្មែរ គេឃើញ :

+ ព្រហ្មញ្ញសាសនា មានបារ៉មី ៣

១. ព្រះព្រហ្ម

២. ព្រះឥសូរ

៣. ព្រះនារាយណ៍

+ ពុទ្ធសាសនា មានបារ៉មី ៣ ដែរ

១. ព្រះពុទ្ធ

www.elibraryofcambodia.org

២. ព្រះធម៌

៣. ព្រះសង្ឃ ។

ថ្ងៃក្រោយមក ឃើញខ្មែរដូរបាវចនារបស់ខ្លួនថា ជាតិ សាសនា ព្រះមហាក្សត្រ

ខ្មែរបានដូរបាវចនាពី ៥ មក ៣ ប្រហែលជាសម័យមុន ការកសាងប្រាសាទអង្គរវត្ត បានជាប្រាសាទអង្គរវត្ត មានកំពូល៥ បើយើងមើលពីលើ, ពីចំហៀង, បើយើងមើលពីខាងមុខ ពីក្រោយ ឃើញប្រាសាទអង្គរវត្ត មានកំពូល ៣ ។

**តាមទស្សនៈផ្ទាល់ខ្លួន**

**ក.** ដោយស្រុកក្រផង ប្រជាជនហាក់ដូចជាអស់ជំនឿផង នៅពេលរៀបការកូនចៅ គ្មានបានរៀប ៖

- ពិធីធ្វើធ្មេញ
- ពិធីហៅព្រលឹង
- ពិធីដាំបាយព្រលឹង
- គ្មានបាយព្រលឹងដាក់តៀប បានជាឃើញនៅសល់តែតៀប ២ ។

www.elibraryofcambodia.org

៦. នៅពេលនោះ ហាក់ដូចជាមានទ្រីស្តិ និយមគូ នៅក្នុងពិធីអាពាហ៍ពិពាហ៍កូនចៅខ្មែរ នៅចុងសតវត្សទី ២០ និងដើមសតវត្សទី ២១ នេះ ដូចជា

- ទៀប ២
- មូស្លាអមខ្លួន ២
- ថង់រង ២
- ស្លាដក ស្លាកន្សែង ២
- ទៀនពេលា ១ គូ,... ។

សូមជួយពិចារណា? តើមកពីមានមូលហេតុអ្វី?

**បញ្ជាក់**

ពីសម័យបុរាណ លោកមានជំនឿថា បើអ្នកណាម្នាក់បានហូបបាយព្រលឹង អ្នកនោះ នឹងមានព្រលឹងទាំង ១៩ ចូលមកស្ថិតនៅក្នុងខ្លួន បានសុខ បានចំរើន មានសិរីសួស្តីគ្រប់ពេលវេលា កុំបីមានចង្រៃឧបទ្រព្យអ្វីកើតមានដល់ខ្លួនឡើយ ។

ដូចនេះ នៅគ្រប់ពិធីទាំងអស់ ដូចជា ពិធីកោរជុក, ចូលម្លប់, ចេញពីម្លប់, បួសសាមណេរ, ភិក្ខុ, ការ, ចំរើនព្រះជន្ម,... លោកបានធ្វើពិធីហៅព្រលឹងទាំងអស់ អោយអ្នកដែលគេរៀបពិធី បានហូបបាយព្រលឹងគ្រប់ៗគ្នា នៅគ្រប់ពិធីទាំងអស់ ។

www.elibraryofcambodia.org

វាយបញ្ចូលជា eBook ដោយ ម៉េង សោភ័ណ្ឌ

ក្រោមការឧបត្ថម្ភពីសំណាក់ ខ្មៅ យុន សំរ៉ង

គាំទ្រពីលោក ជា សារឿន

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ខែ មេសា ឆ្នាំ ២០១៤

មូលនិធិខ្មែរសំរាប់ការសិក្សា

www.elibraryofcambodia.org